# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Apr-2013, 15:28
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ការជំទាស់ទៅនឹងសំណើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារិត

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

Joshua ROSESWEIG
Forest O'NEILL-GREENBERG

**ផ្ញើជូន៖**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង**

**លោក** Andrew CAYLEY

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**
**Elisabeth SIMONNEAU-FORT**

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាស្វែងរកការបញ្ជាក់ពីអង្គជំនុំជម្រះសាលាដំបូងថា កំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់ ត្រូវតែទទួលយកជាភស្តុតាង ឲ្យតែកំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះពាក់ព័ន្ធ និងមានតម្លៃភវនីយភាព (“សំណើដើមរបស់សហព្រះរាជអាជ្ញា[1])។ នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វិធាននីតិវិធីដែលបង្កើតឡើងនៅកម្រិតអន្តរជាតិ ទាក់ទងនឹងការទទួលយកជាភស្តុតាងនូវកំណត់ហេតុនៃការស្តាប់ចម្លើយ អនុវត្តចំពោះដំណើរការនីតិវិធីនៅអវតក (សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ)[2]។ ក្រោយមកសហព្រះរាជអាជ្ញាស្វែងរកឲ្យទទួលយកជាភស្តុតាងនូវកំណត់ហេតុនៃការស្តាប់ចម្លើយ ពាក្យបណ្តឹងរបស់ជនរងគ្រោះ និងសក្ខីកម្មផ្ទាល់មាត់៤០ថ្ងៃពីការជំនុំជម្រះនៅក្នុងករណី០០១ (“សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា)[3]។ ដើមបណ្តឹងរដ្ឋប្បវេណីស្វែងរកការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣.៨៦៦[4] ។

---

[1] ឯកសារ E-96 “សំណើរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៨២ ទាក់ទងនឹងការទទួលយកជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី” ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ERN 00706071-00706086 (“សំណើដើមរបស់សហព្រះរាជអាជ្ញា”) ។

[2] ឯកសារ E-96/7 “សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៨២ ទាក់ទងនឹងការទទួលយកជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារដទៃទៀត” ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ERN 00812146-00812163 (សេចក្តីសម្រេចលើកំណត់ស្តាប់ចម្លើយសាក្សី”)។

[3] ឯកសារ E-96/8 “សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា សុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់នៃការហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារិត ព្រមជាមួយឧបសម្ព័ន្ធសម្ងាត់១ រហូតដល់១៦” ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០១២ ERN 00828859-00828873; E208; E208/2 (ជាមួយ “សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា”)។

[4] ឯកសារ E-208/4.1 “ចម្លើយតបរបស់សហមេធាវីនាំមុខនៃដើមបណ្តឹងរដ្ឋប្បវេណីចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៨២ ទាក់ទងនឹងការទទួលយកជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងឯកសារដទៃទៀត(E-96/7) និងទៅនឹងអនុស្សរណៈ E-208/3 រួមទាំងឧបសម្ព័ន្ធសម្ងាត់១ និង២” ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ ERN 00842448-00842463

២. នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងណែនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីឲ្យដាក់មិនហួសពីថ្ងៃទី ៤ ខែ មិនា ឆ្នាំ ២០១៣ នូវបញ្ជីនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនដែលបានកែប្រែ និងបញ្ជាក់បន្ថែមពីភាពពាក់ព័ន្ធរបស់កំណត់ហេតុនៃការស្តាប់ចម្លើយមួយណាដែលសហមេធាវីនាំមុខមានបំណងដាក់ជាភស្តុតាង ("អនុស្សរណៈខែតុលា") ។ អង្គជំនុំជម្រះបានចង្អុលបង្ហាញបន្ថែមថា ក្រុមមេធាវីការពារក្តីអាចដាក់ការជំទាស់រហូតដល់ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣[5] ។

៣. នៅថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តីបានដាក់ការឆ្លើយតបជាបឋមទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ("ការឆ្លើយតបបឋម")[6]។ ចម្លើយតបបឋមបានធ្វើការសន្និដ្ឋានលម្អិតទាក់ទងនឹងរបបគតិយុត្តិដែលបង្កើតឡើងនៅតុលាការមិនអចិន្ត្រៃយ៍នានា និងប្រសិទ្ធភាពនៃរបបគតិយុត្តិនេះ ទាក់ទងនឹងការទទួលយកនូវប្រភេទកំណត់ហេតុស្តាប់ចម្លើយដែលទូលំទូលាយ និងដោយសម្រាំង។ ក្រុមមេធាវីការពារក្តីស្វែងរកការបញ្ជាក់ពីអង្គជំនុំជម្រះលើច្បាប់ដែលយកមកអនុវត្តនៅចំពោះ អវតក និងប្រកាសថាប្រភេទមួយចំនួន នៃកំណត់ហេតុស្តាប់ចម្លើយ គឺមិនអាចទទួលយកបានឡើយ[7] ។

៤. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាស្វែងរកការអនុញ្ញាតដើម្បីឆ្លើយតបនៅក្រោយថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ នៅក្នុងចម្លើយតបរួមមួយទៅនឹងសេចក្តីសន្និដ្ឋានទាំងអស់របស់ក្រុមមេធាវីការពារក្តីទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី[8]។ អង្គជំនុំជម្រះអនុញ្ញាតលើសំណើនេះ តែមិនបានផ្តល់ការបញ្ជាក់ទាក់ទងនឹងច្បាប់ដែលយកមកអនុវត្តនៅមុនកាលបរិច្ឆេទកំណត់ដែលនៅជាធរមាន។

---

[5] អនុស្សរណៈ E-208/2 អនុស្សរណៈពីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ERN 00852923-00852926 ("អនុស្សរណៈខែតុលា")។

[6] ឯកសារ E-96/8/1 "ចម្លើយតបបឋមទៅនឹងសំណើបន្ថែមរបស់ព្រះរាជអាជ្ញាដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារិត" ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២ ("ចម្លើយតបបឋម")។

[7] ការឆ្លើយតបបឋម កថាខណ្ឌទី៤៧ ។

[8] សារអ៊ីម៉ែលចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ពីលោក Bill Smith ទៅកាន់ភាគីទាំងអស់ ។

៥. នៅថ្ងៃទី ៤ ខែ មិនា ឆ្នាំ ២០១៣ ដើមបណ្តឹងរដ្ឋប្បវេណីដាក់បញ្ជីនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានកែសម្រួលឡើងវិញ ដែលពួកគេមានបំណងស្វែងរកការទទួលយកជាភស្តុតាងនៅសវនាការ[9]។ នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣ ក្រុមមេធាវីការពារ ខៀវ សំផន បានដាក់ការជំទាស់របស់ពួកគេទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយ ("ការជំទាស់របស់ ខៀវ សំផន")[10]។ នៅថ្ងៃទី១០ ខែ មេសា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាដាក់បញ្ជីកំណត់ហេតុស្តាប់ចម្លើយដែលបានកែសម្រួល ដែលបានកាត់បន្ថយចំនួនកំណត់ហេតុ ដែលសហព្រះរាជអាជ្ញាបានស្វែងរកឱ្យទទួលយកជាភស្តុតាង និងបានកែប្រែនូវអំពើ និងសកម្មភាពរបស់ជនជាប់ចោទពីកំណត់ហេតុស្តាប់ចម្លើយចំនួន២២០ ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះ ("សំណើចុងក្រោយ")[11]។

## II. ច្បាប់ដែលពាក់ព័ន្ធ

### ក. ចម្លើយតបបឋមថែងពីការវាយតម្លៃរបបកតិយុត្តិត្រឹមត្រូវ

#### i- គោលការណ៍តតិយុត្តិនៅក្នុងចម្លើយតបបឋមឆ្លុះបញ្ចាំងពីច្បាប់របស់តុលាការមិនអចិន្ត្រៃយ៍

---

[9] ឯកសារ E-223/2/7 "ចម្លើយតបរបស់សហមេធាវីនាំមុខនៃដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះលើការទទួលយកជាភស្តុតាងនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារដទៃទៀត (ជាមួយឧបសម្ព័ន្ធសម្ងាត់បំផុត) ចុះថ្ងៃទី៤ ខែមិនា ឆ្នាំ២០១៣ ERN 0892286-0892299 ។

[10] ឯកសារ E-277 Conclusions relatives au droit applicable au versement aux débats de déclarations écrites en lieu et place de témoignages oraux déposées en application de la règle 92', 9 April 2013, ERN 00897796-00897814 "ការជំទាស់របស់ ខៀវ សំផន)។

[11] ឯកសារ E-278 "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានៃឧបសម្ព័ន្ធ១២ និង១៣ ដែលបានកែប្រែក្នុងបញ្ជីឯកសារសម្រាប់សវនាការរបស់ខ្លួន អនុលោមតាមវិធាន៨០(៣) (កំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹង) ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៣ ERN 00897846-00897861 (សំណើចុងក្រោយរបស់សហព្រះរាជអាជ្ញា)។

៦. ការឆ្លើយតបជាបឋមរួមបញ្ចូលទាំងសេចក្តីសន្និដ្ឋានលម្អិតទាក់ទងនឹងរបបគតិយុត្តិសម្រាប់ទទួលកំណត់ហេតុស្តាប់ចម្លើយសាក្សី ជំនួសឲ្យការផ្តល់សក្ខីកម្មនៅតុលាការមិនអចិន្ត្រៃយ៍ (វិធាន៩២ស្ទួនរបស់ ICTY)[12]។ មេធាវីការពារក្តីបញ្ចូលសារណាទាំងនោះដោយការយោង។

៧. មេធាវីការពារក្តីកត់សម្គាល់ថា សហព្រះរាជអាជ្ញាយល់ស្របជាមួយការឆ្លើយតបជាបឋម សារៈសំខាន់នៃកំណត់ហេតុស្តាប់ចម្លើយសាក្សីចំពោះការចោទប្រកាន់ និងភាពនៅជិតរបស់វានឹងជនជាប់ចោទ ដែលទាំងពីរចំនុចនេះពាក់ព័ន្ធនឹងបញ្ហាថា តើកំណត់ហេតុស្តាប់ចម្លើយនេះត្រូវទទួលយកដោយពុំមានចាំបាច់ឲ្យសួរដេញដោលសាក្សីដែរ ឬយ៉ាងណា[13]។ តាមពិតតុលាការតែងតែពិចារណាកត្តាទាំងនោះនៅមុនពេលទទួលយកកំណត់ហេតុដោយមិនមានការសួរដេញដោល និងបានបង្កើតនូវរបៀបសម្រាប់អនុវត្ត[14]។ "លក្ខណៈវិនិច្ឆ័យចម្បង"នៅក្នុងការវិភាគគឺ "កាតព្វកិច្ចរបស់អង្គជំនុំជម្រះក្នុងការធានាថាការជំនុំជម្រះមានយុត្តិធម៌"[15]។ ដូចដែលសហព្រះរាជអាជ្ញាបានលើកអំណះអំណាងថ្មីៗនេះ ហើយអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញ សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិអាចកែប្រែឡើងវិញបាន ប្រសិនបើសេចក្តីសម្រេចនេះខកខានមិនបានលើកមកពិចារណាលើការពិចារណានានាដែលពាក់ព័ន្ធទេនោះ[16]។

---

[12]ការចម្លើយតបជាបឋម កថាខណ្ឌទី៦, ១៦, ២៣ និង២៧ ។

[13] សំណើចុងក្រោយរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌទី២៨ ។

[14] ការចម្លើយតបជាបឋម កថាខណ្ឌ12-13 ។

[15] រឿក្តីរដ្ឋអាជ្ញា តទល់ *Sikirica* et al., IT-95-8-T, "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំដាក់ប្រតិចារិតក្រោមវិធាន៩២ ស្ទួន" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២00១ ។ មន្តគាថានោះត្រូវបានលើកឡើងជាច្រើនដងដោយអង្គជំនុំជម្រះនៅតុលាការមិនអចិន្ត្រៃយ៍នានា ។ សូមមើលឧទាហរណ៍រឿងក្តីរដ្ឋអាជ្ញា តទល់ *Brdjanin and Talic*, IT-99-36-T, "អត្ថបទជាសាធារណៈនៃសេចក្តីសម្រេចលើការទទួលយកជាភស្តុតាងកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាមវិធាន៩២ ស្ទួន ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ២00២" ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២00២ នៅកថាខណ្ឌ១១ ។ រឿងក្តីរដ្ឋអាជ្ញា តទល់ . *Milsoevic*, IT-02-54-T, "សេចក្តីសម្រេចលើសំណើរបស់ព្រះរាជអាជ្ញាស្នើសុំដាក់កំណត់ហេតុជាលាយលក្ខណ៍ដែលដាក់នៅក្រោមវិធាន៩២ ស្ទួន" ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២00២ នៅកថាខណ្ឌ៧

[16] ឯកសារ E-163/5/1/1 "បណ្តឹងសារទុក្ខភ្លាមរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះករណី00២/0១ ជាមួយឧបសម្ព័ន្ធ I និងឧសម្ព័ន្ធសម្ងាត់ II" ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១២ ERN

ii. <u>គោលការណ៍ច្បាប់នៅក្នុងចម្លើយតបបឋម ត្រូវតែបានទទួលយកដោយអង្គជំនុំជម្រះ</u>

៨. សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយយល់ឃើញថា ការទទួលយកជាភស្តុតាងនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីនៅ អវតក ត្រូវបានគ្រប់គ្រងដោយវិធាននានានៅតុលាការអន្តរជាតុនីយកម្មនានា ។ អង្គជំនុំជម្រះពន្យល់៖

> ក្របខណ្ឌច្បាប់ និងយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ និងតុលាការអន្តរជាតូនីយកម្មនានាបានថ្លឹងថ្លែងទៅលើកក្តាមួយចំនួន នៅពេលធ្វើការសម្រេចថា តើត្រូវទទួលយកឬមិនទទួលភស្តុតាងនៅក្នុងទម្រង់ជាកំណត់ហេតុចម្លើយ ឬប្រតិចារិតដោយមិនចាំបាច់តម្រូវឲ្យមានវត្តមានសាក្សីទាំងនោះផ្តល់ចម្លើយ ឬអ្នកធ្វើប្រតិចារិតទាំងនោះនៅក្នុងតុលាការឡើយ។ នៅក្នុងបរិបទនៃការជំនុំជម្រះឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ អង្គជំនុំជំម្រះពិចារណាលើវិធាន និងយុត្តិសាស្ត្រទាំងនេះ ដើម្បីបង្កើតឲ្យមានតុល្យភាពមួយរវាងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ និងប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ជាពិសេសដំណើរការជំនុំជម្រះឲ្យបានឆាប់រហ័ស[17]។

៩. ដោយឈរលើមូលដ្ឋាននោះ គោលការណ៍ច្បាប់ដែលមាននៅក្នុងចម្លើយតបបឋម ដែលឆ្លុះបញ្ចាំងពីច្បាប់របស់តុលាការមិនអចិន្ត្រៃយ៍ គួរតែត្រូវគ្រប់ដណ្តប់លើ។ ពិតណាស់សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយមិនដែលទទួលស្គាល់ លើការងាកចេញណាមួយពីការអនុវត្តនៅកម្រិតអន្តរជាតិឡើយ។ តែសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយមិនស្របជាមួយច្បាប់របស់តុលាការមិនអចិន្ត្រៃយ៍នានាក្នុងលក្ខណៈជាច្រើន។ សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយយល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយដែលមិនមានភស្តុតាងនៃអំពើ និងសកម្មភាពរបស់ជនជាប់ចោទ អាចទទួលយកបានដោយមិនចាំបាច់ផ្តល់សក្ខីកម្មផ្ទាល់មាត់ ដោយពុំចាំបាច់ពិចារណាជាបឋមពីកត្តាពាក់ព័ន្ធថា តើការផ្តល់សក្ខីកម្មផ្ទាល់

---

00859078-00859107, paras 21-41 ។ ឯកសារ E-163/5/1/13 "សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមរបស់សហព្រះអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងវិសាលភាព នៃការជំនុំជម្រះករណី០០២/០១ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ ERN 00885759-00885785, នៅកថាខណ្ឌ៣៥-៣៦, ៤០, ៤៤ ។

[17] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយនៅកថាខណ្ឌ២០ ។

តម្រូវ ឬយ៉ាងណាទេ[18]។ ជាងនេះទៅទៀតសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយមិនបានអនុលោមច្បាស់លាស់ទៅនឹងលក្ខខណ្ឌនៃការធ្វើវិញ្ញាបនកម្ម ដែលមានចែងនៅក្នុងវិធាន៩២ស្ទួន(ខ)របស់តុលាការ ICTY ឡើយ[19]។ ការងាកចេញពីបទដ្ឋានអន្តរជាតិនេះគឺគ្មានយុត្តិកម្មទេ។

១០. ជាបឋមនីតិវិធីនៅ អវតក ផ្អែកជាបឋមលើច្បាប់កម្ពុជា[20]។ ការងាកចេញពីច្បាប់កម្ពុជាអាចធ្វើបានតែសមស្របតាមការលើកលែងចង្អៀត ដែលមានចែងនៅក្នុងមាត្រា២១(១)នៃកិច្ចព្រមព្រៀង អវតក និងមាត្រា៣៣ថ្មីនៃច្បាប់ អវតក ប៉ុណ្ណោះ។ បទប្បញ្ញត្តិទាំងនេះដែលសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយផ្អែក[21] អនុញ្ញាតឱ្យអង្គជំនុំជម្រះស្វែងរកការណែនាំនៅក្នុងវិធាននីតិវិធីដែលបង្កើតឡើងនៅកម្រិតអន្តរជាតិ។ យន្តការដែលចែងនៅក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយនៅមិនសមស្របតាមនីតិវិធីនេះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះគប្បីប្រតិបត្តិហួសពីដែនកំណត់នៃយុត្តាធិការរបស់ខ្លួននៅក្នុងការអនុវត្តវា។

១១. ទីពីរយន្តការដែលបង្កើតឡើងដោយអង្គជំនុំជម្រះ គឺមិនសមស្របតាមលក្ខខណ្ឌតម្រូវនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយហេតុដូច្នេះ មិនសមស្របជាមួយមាត្រា៣៣ថ្មីនៃច្បាប់បង្កើត អវតក[22]។ នៅក្នុងចំណុចនេះ សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ

---

[18] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយនៅកថាខណ្ឌ២៥ ។

[19] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយនៅកថាខណ្ឌ២៨ ។

[20] កិច្ចព្រមព្រៀង មាត្រា១២(១)។ (នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា) ។ មាត្រា ៣៣ថ្មី នៃច្បាប់បង្កើត អវតក (ការជំនុំជម្រះត្រូវធ្វើឡើងទៅតាមនីតិវិធីដែលនៅជាធរមាន)។

[21] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយនៅអក្សរក្នុងលេខយោង៣៧ ។

[22] ច្បាប់ អវតក មាត្រា៣៣ថ្មី (អវតក ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចមានចែងនៅក្នុងមាត្រា ១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សូមមើលផងដែរ រឿងក្តី *Dimar Sibgatullin v. Russia*, ECtHR ពាក្យបណ្តឹងលេខ 1413/05 "សាលក្រម" ចុះថ្ងៃ២៤ ខែមេសា ឆ្នាំ២០១២ នៅកថាខណ្ឌ៥៧ (ជនជាប់ចោទមានសិទ្ធិ "ត្រួតពិនិត្យទៅតាមរបៀបដែលសាក្សីត្រូវបានស្តាប់ចម្លើយដោយអ្នកស៊ើបអង្កេត និង វាយតម្លៃភាពជឿទុកចិត្តនៃអ្នកចោទប្រកាន់ប្រឆាំងនឹងរូបគាត់)។

សំអាងច្បាប់ពីប្រភពជាច្រើន រួមទាំង ICCPR តុលាការសិទ្ធិមនុស្សអឺរ៉ុប និងតុលាការមិនអចិន្ត្រៃយ៍នានា[23]។ អង្គជំនុំជម្រះយល់ឃើញថា ICCPR ធានាជនជាប់ចោទនូវ "ឱកាសដាក់សំនួរ និងជំទាស់សាក្សីប្រឆាំងរូបគាត់នៅដំណាក់កាលមួយចំនួននៃកិច្ចដំណើរនីតិវិធី[24]។ ឱកាសនោះត្រូវបានបដិសេធក្នុងអំឡុងពេលស៊ើបអង្កេតសម្រាប់មូលហេតុយ៉ាងច្បាស់ថា ការតទល់នឹងនឹងមាននៅសវនាការ:

> បើទោះបីការតទល់នៅដំណាក់កាលនេះនៃនីតិវិធីឆ្លើយតបទៅនឹងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទដើម្បីពិនិត្យ ឬបានពិនិត្យសាក្សីប្រឆាំងនឹងគាត់ ដូចមានចែងនៅក្នុងមាត្រា១៤(ង) នៃ [ICCPR] ក៏ពុំមានសិទ្ធិដាច់ខាតដើម្បីធ្វើការតទល់បែបនេះនៅដំណាក់ស៊ើបសួរដែរ។ *សម្រាប់មូលហេតុនេះ វិធាន ៨៣(៣) ទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទដើម្បីពិនិត្យនៅដំណាក់ជំនុំជម្រះសាក្សីប្រឆាំងនឹងគាត់ដែលគាត់មិនត្រូវបានអនុញ្ញាតឱ្យតទល់ក្នុងអំឡុងពេលស៊ើបសួរ។ ហេតុដូច្នេះ ដោយពិចារណាលើកិច្ចនីតិវិធីទាំងមូល នីតិវិធីធានាឱ្យគោរពយ៉ាងពេញលេញចំពោះលក្ខខណ្ឌតម្រូវនៅក្នុង ICCPR*[25]។

១២. យុត្តាធិការតុលាការសិទ្ធិមនុស្សអឺរ៉ុបដែលអង្គជំនុំជម្រះលើកមកសំអាងនៅក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ មានបំណងថាសិទ្ធិរបស់ជនជាប់ចោទដើម្បីតទល់សាក្សីពិសេសណាមួយ ត្រូវកំណត់ឡើងដោយសារៈសំខាន់នៃភស្តុតាងចំពោះរឿងក្តីទាំងមូល និង

---

[23] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយនៅអក្សរក្នុងលេខយោង១៩ ។

[24] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយនៅអក្សរក្នុងលេខយោង១៩ ។

[25] ឯកសារ A-110/1 អនុស្សរណៈពីសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២00៨ ERN 00157729-00157730, p. 2 (បញ្ជាក់បន្ថែម)។ ចាប់តាំងពីដំណាក់កាលដំបូងនៃកិច្ចស៊ើបសួរ មេធាវីការពារក្តីស្វែងរកការតំណាងនៅពេលយកចម្លើយ និងបានជំទាស់ច្រើនលើកច្រើនសារ និងខ្លាំងៗអំពីភាពខ្វះចន្លោះនៅក្នុងវិធីសាស្ត្រស៊ើបសួរ។ សូមមើលឯកសារលេខ A-110 លិខិត: កម្មវត្ថុ៖ "កិច្ចដំណើរការស៊ើបសួរ" ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២00៧, ERN 00157351-00157352 ។ ឯកសារ D-171/2 "ការជូនដំណឹងនៃសំណើរួមចំពោះសំណើលើកទីបីរបស់ អៀង ធិរិទ្ធ សុំបើកកិច្ចស៊ើបសួរ" ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២00៩, ERN 00337488-00337489 ។ ឯកសារ E-234/2 "ការជូនដំណឹងនៃសំណើរួមចំពោះសំណើ E-234 របស់ អៀង សារី" ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១២ ERN 00858861-00858876 នៅក្នុងអក្សរក្នុងលេខយោង១៧។

វិសាលភាពដែលវាត្រូវបានផ្អែកដោយតុលាការ[26]។ នីតិវិធីនៅដែលជាធរមាននៅតុលាការមិនអចិន្ត្រៃយ៍ផ្តល់ឱ្យជនជាប់ចោទនូវឱកាសបង្កើតករណីនោះយ៉ាងច្បាស់: ស្នើសុំឱ្យតុលាការថាសារៈសំខាន់របស់ភស្តុតាង មានទំហំធំធេងណាស់ដែលអនុញ្ញាតឱ្យទទួលយកដោយពុំចាំបាច់ការផ្តល់សក្ខីកម្មផ្ទាល់មាត់[27]។ តាមពិតដូចដែលសហព្រះរាជអាជ្ញាបាន កត់សម្គាល់អញ្ចឹង តុលាការមិនអចិន្ត្រៃយ៍នានាសំអាងតុលាការអឺរ៉ុបនៅក្នុងការបង្កើតយន្តការនីតិវិធីរបស់ពួកគេ[28]។ ហេតុដូច្នេះ យន្តការនោះបង្ហាញខ្លឹមសារនៃសិទ្ធិជាសារវ័ន្ត ដើម្បីតទល់នៅក្នុងបរិបទការជំនុំជម្រះលើបទឧក្រិដ្ឋធំ ។

១៣. ទីបី ពិចារណាលើចរិតលក្ខណៈឥតលំអៀងនៃកិច្ចស៊ើបសួរ ពុំមានមូលដ្ឋានដែលត្រូវដកចេញពីច្បាប់របស់តុលាការមិនអចិន្ត្រៃយ៍[29] ។ ប្រព័ន្ធច្បាប់បារាំងដែលនីតិវិធីកម្ពុជាទាញយកធានាសិទ្ធិរបស់ជនជាប់ចោទក្នុងការតទល់សាក្សីនៅដំណាក់ស៊ើបសួរ[30]។

---

[26] រឿងក្តី *Delta v. France*, ECtHR, ពាក្យបណ្តឹងលេខ 11144/85 "សាលក្រម" ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩០ នៅកថាខណ្ឌ៣៧ (ការរំលោភមាត្រា ៦(៣) របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដោយសារតុលាការផ្អែកលើកំណត់ស្តាប់ចម្លើយសាក្សី ដែលត្រូវបានស្នើឱ្យចូលខ្លួនដោយមេធាវីការពារក្តី ប៉ុន្តែត្រូវបានបដិសេធ) ។ រឿងក្រី *Unterpertinger v. Austria*, ECtHR, ពាក្យបណ្តឹងលេខ 9120/80 "សាលក្រម" ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៨៦ នៅកថាខណ្ឌ 32-33 (បើទោះបីកំណត់ហេតុជាលាយលក្ខណ៍មិនត្រឹមតែបង្កើតបានជាភស្តុតាងនៅចំពោះមុខតុលាការទេ តែការវិនិច្ឆ័យទោសផ្អែកជា "សំខាន់" ទៅលើកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី ដែលជនជាប់ចោទរូបនេះមិនត្រូវបាន អនុញ្ញាតឱ្យពិនិត្យទៀតផង) ។ រឿងក្តី *A.S. v. Finland*, ECtHR, "ពាក្យបណ្តឹងលេខ 40156/07 "សាលក្រម" ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ 48-75 (ភស្តុតាងដែលធម្មតាត្រូវតែបានផ្តល់ក្នុងដំណាក់កាលកិច្ចដំណើរការនីតិវិធី បើទោះបី "វិធានការជាក់លាក់មួយចំនួន" ចាំបាច់ដើម្បីការពារជនរងគ្រោះជាកុមារ នៅក្នុងករណីនេះពុំមានភស្តុតាងផ្ទាល់ ក្រៅពីភស្តុតាងជាកំណត់ហេតុ ដែលជនជាប់ចោទមិនអាចតទល់បាន) ។

[27] សូមមើលចម្លើយតបបឋម នៅកថាខណ្ឌ 12-13 ។

[28] សូមមើលសំណើដើមរបស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ១១ ។

[29] សូមមើលសំណើដើមរបស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ៣១-៣២ (លើកឡើងថាអង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាលើចរិតលក្ខណៈនៃដំណើរការនីតិវិធីក្នុងច្បាប់ civil law ដែលថាការស៊ើបសួរត្រូវឥតលំអៀង)។ ពិតណាស់ការពិចារណាទាំងនេះមិនពាក់ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយណាមួយ ដែលមិនត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតឡើយ ។

[30] សូមមើល Code de Procédure Pénale, Art. 120 ('Le juge d'instruction dirige les interrogatoires, confrontations et auditions. Le procureur de la République et les avocats des parties et du témoin assisté

សហចៅក្រមស៊ើបអង្កេត ដែលទាំងពីរនាក់មានពូជពង្សពីច្បាប់ច្បាប់ civil law បានបដិសេធសិទ្ធិក្នុងការទទួលបានសិទ្ធិដាច់ខាតក្នុងការតទល់នៅដំណាក់កាលជំនុំជម្រះ ជាបទដ្ឋានខ្ពស់ជាងបទដ្ឋានដែលអនុវត្តនៅតុលាការមិនអចិន្ត្រៃយ៍នានា។

iii- អង្គជំនុំជម្រះសាលាដំបូងទទួលបានឆន្ទានុសិទ្ធិយ៉ាងច្រើនអនុលោមតាមសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ

១៤. សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយណែនាំថា បន្ទាប់ពីអង្គជំនុំជម្រះសន្និដ្ឋានថាកំណត់ហេតុស្តាប់ចម្លើយជាលាយអក្ខណ៍អក្សរមិនមានភស្តុតាងនៃអំពើ និងសកម្មភាពរបស់ជនជាប់ចោទ ជាបន្ទាប់អង្គជំនុំជម្រះសម្រេចលើការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនថា តើអង្គជំនុំជម្រះគួរតែទទួលយក[31]។ ការពិចារណាទាំងអស់ដែលសំអាងនៅក្នុងចម្លើយតបបឋម គឺពាក់ព័ន្ធទៅនឹងការពិភាក្សានោះ ហើយអាចបង្កើតជាមូលដ្ឋានត្រឹមត្រូវនៃការសម្រេចមិនទទួលយកកំណត់ហេតុស្តាប់ចម្លើយជាភស្តុតាង[32]។

**ខ. កំណត់ហេតុស្តាប់ចម្លើយជាន់គ្នាដែលមិនចាំបាច់ មិនទទួលយក**

១៥. ក្រុមមេធាវីស្របគ្នាជាមួយក្រុមមេធាវីការពារក្តី ខៀវ សំផន ថាអង្គជំនុំជម្រះមានសិទ្ធិបដិសេធកំណត់ហេតុជាលាយលក្ខណ៍អក្សរនៅពេលដែលភស្តុតាងនៅក្នុងកំណត់ហេតុស្តាប់

---

peuvent poser des questions ou présenter de brèves observations.'), Art. 82.1 ('Les parties peuvent, au cours de l'information, saisir le juge d'instruction d'une demande écrite et motivée tendant à ce qu'il soit procédé à leur audition ou à leur interrogatoire, à l'audition d'un témoin, à une confrontation ou à un transport sur les lieux, à ce qu'il soit ordonné la production par l'une d'entre elles d'une pièce utile à l'information, ou à ce qu'il soit procédé à tous autres actes qui leur paraissent nécessaires à la manifestation de la vérité.')។

[31] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយនៅអក្សរក្នុងលេខយោង២៤ ។

[32] *រឿងក្តីរដ្ឋអាជ្ញា Galic*, IT-98-29-AR73.2, "សេចក្តីសម្រេចលើបណ្តឹងបន្ទាន់បង្ខំទាក់ទងនឹងវិធាន៩២ស្ទួន(គ) ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០២ នៅកថាខណ្ឌ១៣ ។ រឿងក្តីរដ្ឋអាជ្ញាតទល់ *Brdjanin and Talic*, IT-99-36-T, "អត្ថបទសាធារណៈនៃសេចក្តីសម្រេចសម្ងាត់ស្តីពីការទទួលយកភស្តុតាងតាមវិធាន៩២ស្ទួន ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ២០០២, ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០២ កថាខណ្ឌ១៤ ។ រឿងក្តីរដ្ឋអាជ្ញាតទល់ *Bagosara et a.*, ICTR-98-41-T "សេចក្តីសម្រេចលើញត្តិសុំទទួលយកជាភស្តុតាងកំណត់ហេតុជាលាយអក្សរនៅក្រោមវិធាន៩២ស្ទួន" ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ២០០៤ នៅកថាខណ្ឌ១៤ ។

ចម្លើយ "ត្រូតគ្នាដោយមិនចាំបាច់ទៅលើកំណត់ហេតុដទៃទៀត ឬភស្តុតាងដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះ[33]។ អនុលោមតាមអង្គជំនុំជម្រះនៅក្នុងករណី *Blagojevic* អង្គជំនុំជម្រះ "អាចបដិសេធភស្តុតាង ប្រសិនបើតម្លៃភស្តុតាងនីយភាពសំខាន់ជាងសេចក្តីត្រូវការការ ជំនុំជម្រះដោយយុត្តិធម៌"[34]។ ការវិភាគលើលក្ខណៈពិសេសរបស់វិធាន៩២ស្ទួន ត្រូវបានទទួលយកដោយអង្គជំនុំជម្រះនៅតុលាការ ICTR[35]។

## III. អំណះអំណាង

### ក. ការជំទាស់នេះធ្វើឡើងទាន់ពេលវេលា

១៦. អង្គជំនុំជម្រះកំណត់កាលបរិច្ឆេទមិនឲ្យហួសពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ សម្រាប់ការជំទាស់ទៅលើឯកសារទាំងឡាយដែលត្រូវបានទទួលយកអនុលោមតាមសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយត[36]។ អាស្រ័យហេតុនេះ ការជំទាស់នេះត្រូវបានដាក់ទាន់ពេលវេលា ។

### ខ. កំណត់ហេតុស្តាប់ចម្លើយភាគច្រើនដែលដាក់ដោយសហព្រះរាជអាជ្ញា មិនអាចទទួលយកជាភស្តុតាងឡើយ

---

[33] ការជំទាស់របស់ ខៀវ សំផន នៅកថាខណ្ឌ (លើកមកសំអាងករណីរដ្ឋអាជ្ញាតទល់ *Krajisnik*, IT-00-39-T, "ដីកាសម្រេចទាក់ទងនឹងសំណើរបស់ព្រះរាជអាជ្ញា សុំទទួលយកភស្តុតាងអនុលោមតាមវិធាន៩២ស្ទួន" ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ នៅទំព័រ២)។

[34] *ករណីរដ្ឋអាជ្ញាតទល់* *Blagojevic and Jokic*, IT-02-60-T, "សេចក្តីសម្រេចលើកទីមួយលើញត្តិរបស់ព្រះរាជអាជ្ញាសុំទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងសក្ខីកម្មមុនៗអនុលោមតាមវិធាន៩២ស្ទួន" ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ នៅកថាខណ្ឌ២០ ។

[35] *ករណីរដ្ឋអាជ្ញាតទល់* *Bagosara et al.*, ICTR-98-41-T, "សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញាសុំទទួលប្រតិចារិតនៅក្រោមវិធាន៩២ស្ទួន" ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០០៤ នៅកថាខណ្ឌ១០ ។ *ករណីរដ្ឋអាជ្ញាតទល់* *Rukundo*, ICTR-2001-70-T, "សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីសុំបង្ហាញសាក្សីបន្ថែម និងសំណុំឯកសារភស្តុតាងនៅមុនការបិទករណី" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅកថាខណ្ឌ១២ ។

[36] អនុស្សរណៈខែតុលា កថាខណ្ឌ១៤ ។

i. <u>សហព្រះរាជអាជ្ញាខកខានមិនបានផ្តល់ឲ្យទាន់ពេលវេលា និងកាត់បន្ថយឲ្យបានគ្រប់គ្រាន់នូវចំនួនកំណត់ហេតុដែលខ្លួនបានដាក់</u>

១៧. នៅមុនរៀបរាប់អំពីប្រភេទនៃការជំទាស់ មេធាវីការពារក្តីកត់សម្គាល់ថាកំណត់ហេតុស្តាប់ចម្លើយក្នុងចំនួនដ៏ច្រើនដែលដាក់ដោយសហព្រះរាជអាជ្ញា នៅតែមិនអាចគ្រប់គ្រងបាន ។ ដូចដែលមេធាវីការពារក្តីកត់សម្គាល់នៅចម្លើយតបបឋម ពីមួយពេលទៅមួយពេល កំណត់ហេតុស្តាប់ចម្លើយដ៏ច្រើនដែលដាក់ដោយសហព្រះរាជអាជ្ញា ត្រូវបានគេមើលឃើញមិនសូវសំខាន់ ដែលសារណាតាមវិធាន៩២ស្ទួនមិនដែលដាក់នៅតុលាការអន្តរជាតិទេ[37]។ បើទោះបីមានឱកាសជាច្រើនដើម្បីកាត់បន្ថយចំនួនកំណត់ហេតុទាំងនេះ សហព្រះរាជអាជ្ញាមិនបានធ្វើឲ្យទាន់ពេលវេលា ឬកាត់បន្ថយឲ្យបានគ្រប់គ្រាន់ឡើយ ។

១៨. នៅ មេសា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាស្វែងរកឲ្យទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹងចំនួន ១៨២៩ ទាក់ទងនឹងករណី០០២ទាំងស្រុង[38]។ នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះនេះណែនាំភាគីបញ្ចៀសការស្វែងរកការដាក់សម្ភារៈក្នុងបរិមាណច្រើន ឬសម្ភារៈជាន់គ្នា" ហើយហេតុដូច្នេះ ណែនាំឲ្យកាត់បន្ថយចំនួនកំណត់ហេតុស្តាប់ចម្លើយដែលមានដាក់ជាភស្តុតាង[39]។ តែសហព្រះរាជអាជ្ញានៅតែបន្តស្វែងរកដាក់កំណត់ហេតុជាង ១៥៨២ ឬ ៨៦% នៃបរិមាណភស្តុតាងសរុបរបស់ពួកគេទាក់ទងនឹងករណី០០២/០១ តែឯកឯង[40]។ អង្គជំនុំជម្រះកត់សម្គាល់នៅខែ តុលា ឆ្នាំ ២០១២

---

[37] ចម្លើយតបបឋមនៅកថាខណ្ឌ៣ ។

[38] សំណើដើមរបស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ២។

[39] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ នៅកថាខណ្ឌ៣៥។

[40] ឯកសារ E-96/8.2 "ឧបសម្ព័ន្ធ I-កំណត់ហេតុស្តាប់ចម្លើយសាក្សីៈ ភស្តុតាងគាំទ្រ" ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ ERN 00859386-00859406 (ចុះឈ្មោះសាក្សី១៧៧នាក់ ដែលកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេ ត្រូវបានដាក់សម្រាប់ស្វែងរកឲ្យទទួលយកជាភស្តុតាង) ។ ឯកសារ E-208/2.3 "ឧបសម្ព័ន្ធ III" ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ ERN 00822498-00822499 (ចុះបញ្ជីសាក្សី៥១នាក់ ដែលកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេ ត្រូវបានដាក់សម្រាប់ឲ្យទទួលយកជាភស្តុតាង)។

ថាសហព្រះរាជអាជ្ញាមិនកាត់បន្ថយឱ្យបានច្រើននូវចំនួនកំណត់ហេតុស្តាប់ចម្លើយដែលបានដាក់ឡើយ “បើទោះបីត្រូវបានស្នើសុំឱ្យកាត់បន្ថយក៏ដោយ”[41]។

១៩. នៅពេលខែ មករា ដល់ខែកុម្ភៈ ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាធ្វើបច្ចុប្បន្នភាពដល់ភាគីអំពីកិច្ចប្រឹងប្រែងដែលកំពុងបន្តធ្វើដើម្បីកាត់បន្ថយបញ្ជីនៃកំណត់ហេតុស្តាប់ចម្លើយនោះ ដោយបានបង្ហាញថាកំណត់ហេតុស្តាប់ចម្លើយស្មើនឹង ៤០% ឬអាចច្រើនជាងនេះ អាចនឹងដកចេញ[42]។ សហព្រះរាជអាជ្ញារងអន្តរជាតិបានកត់សម្គាល់ថាការកាត់បន្ថយកំណត់ហេតុស្តាប់ចម្លើយនេះ នឹង “កាត់បន្ថយជាច្រើននូវបន្ទុកការងារសម្រាប់ភាគីទាំងអស់នៅក្នុងការពិនិត្យកំណត់ហេតុទាំងនេះ និងរៀបចំការជំទាស់ប្រឆាំងនឹងកំណត់ហេតុស្តាប់ណាមួយ”[43]។ ភ្លាមៗបន្ទាប់ពី អង្គជំនុំជម្រះតុលាការកំពូលមោឃភាពសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុង ការបំបែកការជំនុំជម្រះករណី០០២ សហព្រះរាជអាជ្ញាស្នើឱ្យពន្យារកិច្ចដំណើរការនីតិវិធី ដែលរៀបរាប់នៅក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ និងអនុស្សរណៈខែតុលា[44] អង្គជំនុំជម្រះសាលាដំបូងបដិសេធ[45]។ តែសហព្រះរាជអាជ្ញាជ្រើសរើសមិនបានដាក់បញ្ជី ដែលបានកែសម្រួលរហូតដល់ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣[46]។ បើទោះបីជាបញ្ជីនោះមានកំណត់ហេតុស្តាប់ចម្លើយតែ១.០៤០ ក៏កំណត់ហេតុស្តាប់ចម្លើយជាច្រើននៅតែមានភាពពាក់ព័ន្ធតិចតួច ឬមិនមានភាពពាក់ព័ន្ធចំពោះដំណើរការនីតិវិធី[47]។

<u>ii- ភស្តុតាងនៅក្រៅវិសាលភាពនៃករណី០០២/០១ មិនអាចទទួលយកឡើយ</u>

២០. កំណត់ហេតុស្តាប់ចម្លើយមួយធំដែលបានដាក់ក៏ពាក់ព័ន្ធភស្តុតាងពីទីកន្លែងប្រព្រឹត្ត បទល្មើសគឺហួសពីវិសាលភាពនៃករណី០០២/០១។ ដោយសារផលពិបាកដើម្បីធានាសិទ្ធិ

---

[41] អនុស្សរណៈខែតុលា កថាខណ្ឌ៩ ។

[42] សារអ៊ីមែលពីលោក Bill Smith ទៅកាន់ភាគី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣។

[43] សារអ៊ីមែលពីលោក Bill Smith ទៅកាន់ភាគី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣។

[44] សារអ៊ីមែលពីលោក Bill Smith ទៅកាន់ភាគី ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣។

[45] សារអ៊ីមែលពី Susan Lamb ទៅកាន់ភាគី ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣។

[46] សំណើចុងក្រោយរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ២,៤។

[47] សូមមើលកថាខណ្ឌ 20-33 ខាងក្រោម ។

ទទួលការជំនុំជម្រះដោយយុត្តិធម៌ មានទម្ងន់ជាងតម្លៃភវនីយភាពដ៏កម្រិតរបស់កំណត់ហេតុស្តាប់ចម្លើយក្នុងចំនួនច្រើនបែបនេះ។ ហេតុដូច្នេះកំណត់ហេតុស្តាប់ចម្លើយទាំងអស់មិនអាចទទួលបានឡើយ។

*កំណត់ហេតុស្តាប់ចម្លើយមានភាពពាក់ព័ន្ធកម្រិត*

២១. ជាយូរមកហើយអង្គជំនុំជម្រះកម្រិតការផ្តល់សក្ខីផ្ទាល់មាត់នៅតុលាការក្នុងកម្រិតតែវិសាលភាពនៃករណី០០២/០១ ប៉ុណ្ណោះ[48]។ ភស្តុតាងពីអង្គហេតុនៅក្រៅវិសាលភាព ត្រូវបានអនុញ្ញាតតែក្នុងករណីដែលពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល ឬ រចនាសម្ព័ន្ធយោធាប៉ុណ្ណោះ[49]។ ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញា[50] អង្គជំនុំជម្រះមិនដាក់បញ្ចូលយ៉ាងច្បាស់នូវគោលនយោបាយនានាដែលនៅក្រៅពីវិសាលភាពនៃករណី០០២/០១ ពីការជំនុំជម្រះនេះ[51]។

---

[48] ឯកសារ E-145 "អនុស្សរណៈរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ERN 00756549-00756551, pp. 2-3 ។ សូមមើលផងដែរ ឧទាហរណ៍ឯកសារ E-172/10 អនុស្សរណៈពីអង្គជំនុំជម្រះ ចុះថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១២ ERN 00793936 (កំណត់ពីវិសាលភាពនៃការផ្តល់សក្ខីកម្មផ្ទាល់មាត់ចំពោះសាក្សីជាក់លាក់) ។ឯកសារ E-172/27 អនុស្សរណៈពីអង្គជំនុំជម្រះ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ ERN 00816394-0081635 (ស្រដៀងគ្នា)។ ឯកសារ E-1/173.1 ប្រតិចារិតសវនាការ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ERN 00890050-00890119, p. 22:7-11 (សហព្រះរាជអាជ្ញាកត់សម្គាល់ថា ស្តាប់សក្ខីកម្មនៅក្រៅវិសាលភាពករណី០០២/០១ កំហិតត្រឹមតែសាក្សីជាក់លាក់មួយចំនួនទេ)។

[49] សូមមើលឧទាហរណ៍ ឯកសារ E-1/177.1 "ប្រតិចារិតសវនាការ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ ERN 00899302-00899397, pp. 19:13-21:13 (ការជំទាស់ចំពោះសំនួរនានាក្រៅវិសាលភាពមិនអនុញ្ញាត ដោយសារតែវាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ) ។ ឯកសារ E-1/159.1 "ប្រតិចារិតសវនាការ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣ ERN 00879818-00879927, pp. 91:22-93:9 (ស្រដៀងគ្នា)។ ឯកសារ E-1/150.1 "ប្រតិចារិតសវនាការ ចុះថ្ងៃទី7 ខែធ្នូ ឆ្នាំ២០១២ ERN 00870086-00870205, pp 1:23-2:5 (ប្រធានរំលឹកដល់ភាគីឱ្យសួរសំនួរតែគោលនយោបាយអំពីការផ្លាស់ទីប្រជាជន និងរចនាសម្ព័ន្ធ) ។ ឯកសារ E-1/35.1 "ប្រតិចារិតសវនាការ ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១២ ERN 00775428-00775523, pp. 59:13-19 (មេធាវីដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា សំនួរអនុញ្ញាតតែគោលបង្កើតរចនាសម្ព័ន្ធ)។

[50] សំណើចុងក្រោយរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ២៩។

[51] ឯកសារ E-124/7.3 "ឧបសម្ព័ន្ធ" ERN 00852356-00852358, points 1(vii) (កម្រិតតែគោលនយោបាយ JCE ចំពោះតែការផ្លាស់ទីលំនៅប្រជាជននៅដំណាក់ទី១ និងទី២ និងការដោមន្ត្រីសាធារណៈខ្មែរ), ៣(ក)(កម្រិតការចូលរួមនៅក្នុងផែនការរួមចំពោះតែការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ និងដំណាក់កាលទី២ និងការដោមន្ត្រីសាធារណៈខ្មែរ)។

ការដាក់កម្រិតនេះអាចអនុវត្តដោយសមហេតុផលចំពោះចំនួនកំណត់ហេតុលាយលក្ខណ៍ក្នុងចំនួនដ៏ច្រើន ដែលជាបឋមត្រូវបានដាក់ដើម្បីបញ្ជាក់គាំទ្រដល់ការផ្តល់សក្ខីកម្មផ្ទាល់មាត់[52]។

២២. វាច្បាស់ណាស់ជាសំណើរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី សុំដាក់កំណត់ហេតុស្តាប់ចម្លើយធ្វើហួស ពីដែនកំណត់នៃភាពពាក់ព័ន្ធរបស់កំណត់ហេតុស្តាប់ចម្លើយទាំងនេះ ដែលកំណត់ដោយអង្គ ជំនុំជម្រះ។ ទើបតែពីរសប្តាហ៍កន្លងទៅនេះទេ សហព្រះរាជអាជ្ញាស្វះស្វែងឱ្យទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយភាគច្រើនលើសលុបនៅមុនសេចក្តីសម្រេចបំបែកដីកាដំណោះស្រាយ[53]។ សំណើចុងក្រោយរបស់សហព្រះរាជអាជ្ញាស្វែងរកការដាក់ភស្តុតាងនៃ នយោបាយទាំងប្រាំរបស់កម្ពុជាប្រជាធិបតេយ្យ និងភស្តុតាងពីទីតាំងប្រព្រឹត្តទាំងអស់ នៅក្នុងដីកាដំណោះស្រាយ[54]។ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យទទួលស្គាល់ភស្តុតាងស្រដៀងគ្នានេះដែរ[55]។

២៣. តែសហព្រះរាជអាជ្ញាអះអាងថាភស្តុតាងហួសពីវិសាលភាពករណី០០២/០១ គឺជាក់ភស្តុតាងពាក់ព័ន្ធទៅនឹងការបង្កើតអត្ថិភាពនៃគោលនយោបាយ JCE និងការវាយប្រហារទូទៅ និងជាប្រព័ន្ធ[56]។ សហព្រះរាជអាជ្ញាបានលើកអំណះអំណាងថា អង្គហេតុនៅក្រៅវិសាលភាពនៃការជំនុំជម្រះបច្ចុប្បន្ន គឺពាក់ព័ន្ធ ក៏ជាភស្តុតាងប្រយោលទាក់ទងនឹង០០២/០១[57]។ ពុំមានសេចក្តីសន្និដ្ឋានណាមួយក្នុងចំណោមសេចក្តីសន្និដ្ឋានទាំងនេះលើកឡើងពីបញ្ហា ដែលមិនអនុវត្តលើវិសាលភាពនៃការស្តាប់សក្ខីកម្មផ្ទាល់មាត់ឡើយ ហើយត្រូវតែបានទាត់ចោលជាមុន

---

[52] សំណើចុងក្រោយរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ៣៣(ឃ) ។ សំណើបន្ថែមរបស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ៣៨(ខ)។

[53] សូមមើលកថាខណ្ឌ18 ខាងលើ ។

[54] សូមមើលឯកសារ E-278.2 "ការពិនិត្យឡើងនៃឧបសម្ព័ន្ធដែលបានកែប្រែ ១២ និង១៣ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ ERN 00897842-00897845 ។

[55] ឯកសារលេខ **E-223/2/7.2**, "ឧបសម្ព័ន្ធ ១" ថ្ងៃទី ៤ មីនា ឆ្នាំ ២០១៣ ERN 00892301-00892487។

[56] សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ១២។

[57] សំណើដើមរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ៣០-៣៤ ។

ដោយវិធានដែលនៅជាធរមានទាក់ទងនឹងវិសាលភាពនៃការផ្តល់សក្ខីកម្មផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះនេះ[58]។

*កំណត់ហេតុហេតុស្តាប់ចម្លើយដែលមិនជាន់គ្នាទៅលើសក្ខីកម្មផ្ទាល់មាត់*

២៤. ដូចដែលអង្គជំនុំជម្រះបានទទួលស្គាល់ហើយថា តុលាការត្រូវពិចារណាលក្ខណៈត្រួតគ្នានៃកំណត់ហេតុស្តាប់ចម្លើយសាក្សីទៅនឹង សក្ខីកម្មផ្ទាល់ក្នុងសវនាការ[59]។ សហព្រះរាជអាជ្ញាបង្ហាញសក្ខីកម្មមួយចំនួនដូចនេះទាក់ទងនឹងប្រភេទជាក់លាក់លើអង្គហេតុនៅក្រៅវិសាលភាព ០០២/០១ នៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំទទួលយកភស្តុតាង។ ប៉ុន្តែ ជាជម្រើសភស្តុតាងនោះមិនពាក់ព័ន្ធ ផ្ទុយពី និងមិនសមស្របដោយផ្ទាល់ជាមួយនឹងការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។

២៥. *ការកំណត់គោលដៅវាយប្រហារលើពុទ្ធសាសនិក(ឧបសម្ព័ន្ធ១៣):* យុន គីម ផ្តល់សក្ខីកម្មថា វត្តអារាមភាគច្រើន មិនត្រូវបំផ្លាញទេ[60] ហើយថាការហាមឃាត់លើពុទ្ធសាសនា គឺជាផ្នែកនៃបំរាមទូទៅមកលើការប្រតិបត្តិសាសនា[61]។ សៅ សារុន ផ្តល់សក្ខីកម្មថាពុំមានការប្រតិបត្តិពុទ្ធសានាទេ តែមិនមែនដោយសារខ្មែរក្រហមហាមឃាត់ទេ តែដោយសារទីវត្តអារាមទាំងអស់ត្រូវបានបំផ្លិចបំផ្លាញដោយការទម្លាក់គ្រាប់បែករបស់អាមេរិកាំង[62]។ លោក ខៀវ នៅ បានផ្តល់សក្ខីកម្មថា ការប្រតិបត្តិពុទ្ធសាសនាបន្តរហូតជិតពីរឆ្នាំនៅក្រោយ ១៧ មេសា ឆ្នាំ១៩៧៥[63] ហើយថាព្រះសង្ឃត្រូវបានគេដោះជីពរដោយស្មោះចិត្តដោយគ្មានការប្រើកំលាំងឬបង្ខិតបង្ខំឡើយ[64]។ ស្វ ហុង បានផ្តល់សក្ខីកម្មថា គាត់មិនដែលឃើញការធ្វើ ទណ្ឌកម្មចំពោះការបដិសេធមិនព្រមបោះបង់សាសនា ហើយថាពុទ្ធសាសនិកមិនត្រូវបានចាត់ ទុកជា

---

[58] សូមមើលកថាខណ្ឌ 21ខាងលើ ។

[59] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ នៅកថាខណ្ឌ២៤ ។

[60] ឯកសារ E-1/88.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ ទំព័រ. 50:25-51:17 ។

[61] ឯកសារ E-1/88.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ ទំព័រ. 54:24-55:6 ។

[62] ឯកសារ E-1/82.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ ទំព័រ 48:10-49:4។

[63] ឯកសារ E-1/190.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ទំព័រ 10:21-11:12 ។

[64] ឯកសារ E-1/190.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី២១ខែមិថុនា ឆ្នាំ២០១២ ទំព័រ 13:23-14:25 ។

សត្រូវដែរ ហើយថាព្រះសង្ឃត្រូវបានគេដោះជីពរដោយស្មោះចិត្តនៅមុនឆ្នាំ១៩៧៥ ដើម្បីចូលរួមចលនាតស៊ូ[65]។ នី កន បានផ្តល់សក្ខីកម្មថាវត្តអារាមនៅទូទាំងប្រទេសត្រូវបានបំផ្លាញដោយការទម្លាក់គ្រាប់បែកពីអាកាស ដែលជំរុញឲ្យព្រះសង្ឃចូលរួមចលនាតស៊ូ។ គាត់ "មិនបានឮ ឬឃើញបំរាមណាមួយ -ការហាមឃាត់" ទាក់ទងនឹងការ ប្រតិបត្តិសាសនាឡើយ"[66]។

២៦. *ការកំណត់គោលដៅវាយប្រហារលើជនជាតិចាម (ឧបសម្ព័ន្ធ១៤):* យុន គីម ផ្តល់សក្ខីកម្មថាគាត់មិនដែលដឹងអំពីគោលនយោបាយជាក់លាក់ទាក់ទងនឹងជនជាតិចាមហើយថាជនជាតិចាមត្រូវបានគេប្រព្រឹត្តដូចគ្នានឹងខ្មែរទាំងអស់ដែរ[67]។ ខៀវ នៅ ផ្តល់សក្ខីកម្មថាគាត់ពុំមានព័ត៌មានអំពីគោលនយោបាយរបស់ខ្មែរក្រហមចំពោះជនជាតិចិន[68]។

២៧. *ការកំណត់គោលដៅវាយប្រហារលើជនជាតិវៀតណាម (ឧបសម្ព័ន្ធ១៥):* សៅ សារុន បានថ្លែងអំពីឧប្បត្តិហេតុមួយដែលជនជាតិវៀតណាម ត្រូវបានដឹកជញ្ជូនត្រឡប់ទៅវៀតណាម[69] ប៉ុន្តែបានផ្តល់សក្ខីកម្មថា ពុំបានដឹងអំពីគោលនយោបាយ ឬបទបញ្ជាទេ[70]។ គាត់ក៏បានផ្តល់សក្ខីកម្មដែលថា គាត់ទទួលការណែនាំពីមជ្ឈឹមទៅទប់ទល់នឹងវៀតណាមនៅក្នុងបរិបទនៃការឈ្លានពានរបស់វៀតណាមចូលកម្ពុជា[71]។ ខ្ពាន ហ្វីត ផ្តល់សក្ខីកម្មថា គាត់ប្រយ័ត្នប្រយែងមិនហៅវៀតណាមថាជា"យួន" ប៉ុន្តែមួយវិញទៀត ពួកគេជាសត្រូវ[72]។ ជាញឹកញាប់

---

[65] ឯកសារ E-1/66.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ទំព័រ 29:23-30:20។

[66] ឯកសារ E-1/78.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី៣0 ខែឧសភា ឆ្នាំ២០១២ ទំព័រ 28:2-24 ។

[67] ឯកសារ E-1/88.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ ទំព័រ. 54:15-57:2 ។ ឯកសារ E-1/89.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ទំព័រ. 21:16-22:2 ។

[68] ឯកសារ E-1/190.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ទំព័រ 13:23-14:9។

[69] ឯកសារ E-1/82.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ ទំព័រ 42:17-43:7 ។

[70] ឯកសារ E-1/82.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ ទំព័រ 78:14-19, 84:12-85:25. ។

[71] ឯកសារ E-1/84.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ទំព័រ 7:11-22. ។ ឯកសារ E-1/85.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ ទំព័រ 56:12-57:10. ។

[72] ឯកសារ E-1/17.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១២ ទំព័រ 87:19-88:17. ។

នៅដើមឆ្នាំ១៩៧៦ ឬ ១៩៧៧ វៀតណាម ត្រូវបានពិពណ៌នាថាជាសត្រូវ ពិព្រោះវៀតណាម ត្រូវបានចោទប្រកាន់ថា ចូលមកក្នុងទឹកដីកម្ពុជា[73]។

២៨. *អាពាហ៍ពិពាហ៍ដោយបង្ខំ (ឧបសម្ព័ន្ធ១៦)*: លោក យន់ គីម បានផ្តល់សក្ខីកម្មថាលោកជឿថា ទាហានបានរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីដែលមានការព្រមព្រៀងដោយគ្មានការបង្ខំ[74]។ ស្រដៀងគ្នានេះដែរ លោក សៅ សារុន បានផ្តល់សក្ខីកម្មថាអាពាពិពាហ៍ធ្វើឡើងដោយមានការយល់ព្រមពីក្រុមគ្រួសារ ហើយសំខាន់បំផុតនោះ គឺកូនកម្លោះនិងកូនក្រមុំត្រូវតែស្រលាញ់គ្នាទៅវិញទៅមក[75]។ CPLCL កត់សម្គាល់ឃើញថា"គាត់និយាយថាមិនមានការរៀបអាពាពិពាហ៍ដោយបង្ខំទេ[76]"។ សេចក្តីយោងតែមួយគត់ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ក្នុងសក្ខីកម្មរបស់ ខៀវ នៅ ហាក់បីដូចជាពាក់ ព័ន្ធទៅនឹងរឿងរ៉ាវរបស់រូបគាត់ផ្ទាល់[77]។

២៩. ដូចអ្វីដែលវិធាននៃនីតិវិធី និងភស្តុតាងនៅតុលាការ ICTY និង ICTR បញ្ជាក់ច្បាស់រួចហើយ កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី អាចយកទៅបូកបញ្ចូលជាមួយនឹងសក្ខីកម្មផ្ទាល់មាត់បានប្រសិនបើពាក់ព័ន្ធនឹង"អង្គហេតុស្រដៀងគ្នា[78]"។ គ្រាន់តែការពិតមួយដែលថា កំណត់ហេតុស្តាប់ចម្លើយសាក្សីពាក់ព័ន្ធទៅនឹងអង្គហេតុទូទៅដូចគ្នានឹងសក្ខីកម្មផ្ទាល់មាត់របស់សក្ខីមួយចំនួនតូច គឺមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបំពេញតាមបទដ្ឋានខាងលើនោះឡើយ។ តាមពិតទៅ សហព្រះរាជអាជ្ញាបានជម្រុញឲ្យអង្គជំនុំជម្រះទទួលយកភស្តុតាងត្រួតគ្នាដោយសារតែភស្តុតាងនោះ "គ្រាន់តែ" ផ្តល់ព័ត៌មានបន្ថែមចំពោះសក្ខីកម្មផ្ទាល់

---

[73] ដូចខាងលើ ។

[74] សូមមើលឯកសារ E-1/88.1,"ប្រតិចរិតនៃសវនាការ", ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២, pp. 60:15-62:7; ឯកសារ **E-1/89.1**, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២, "ប្រតិចរិតនៃសវនាការ" , pp. 20:11-21:14 ។

[75] ឯកសារ E-1/82.1,"ប្រតិចរិតនៃសវនាការ", ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២, ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២, pp. 67:4-72:21, ឯកសារ **E-1/85.1**, "ប្រតិចរិតនៃសវនាការ", ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២, pp. 28:25-29:16 ។

[76] ឯកសារ **E-1/85.1**,"ប្រតិចរិតនៃសវនាការ", ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២, p. 35:1-3។

[77] ឯកសារ **E-1/90.1**,"ប្រតិចរិតនៃសវនាការ", ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២, pp. 66:7-67:25។

[78] *សូមមើល*វិធាន៩២ ស្ទួន(ក)(i)(a)របស់តុលាការ ICTY , វិធាន៩២ ស្ទួន(ក)(i)(a)របស់តុលាការ ICTR។

មាត់បានឮនៅក្នុងសវនាការតែប៉ុណ្ណោះ[79]។ ប៉ុន្តែការពិតគឺមិនដូចអ្វីដែលបានអះអាងនេះឡើយ ដូច្នេះ មូលហេតុសម្រាប់ទទួលយកភស្តុតាងនេះដែរក៏ត្រូវបដិសេធចោលផងដែរ[80]។

៣០. ការសង្កេតស្រដៀងគ្នានេះអាចធ្វើឡើងពាក់ព័ន្ធនឹងឧបសម្ព័ន្ធ១០ និង១១ ចំពោះសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាដែលពាក់ព័ន្ធនឹងសហករណ៍ និងការដ្ឋាន និងមន្ទីរសន្តិសុខ និងវាលពិឃាត តាមលំដាប់លំដោយ ។ សហព្រះរាជអាជ្ញាខកខានមិនបានបញ្ជាក់អំពី "អង្គហេតុ" ដែលសាក្សីមានឈ្មោះក្នុងឧបសម្ព័ន្ធទាំងពីរនោះបានផ្តល់សក្ខីកម្ម ឬមិនបានបញ្ជាក់ថាតើកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលពួកគេសុំឲ្យទទួលយកជាភស្តុតាងនោះពាក់ព័ន្ធនឹងអង្គហេតុ "ស្រដៀងគ្នា" ដោយរបៀបណា[81]។ ដូចដែលមេធាវីការពារក្តីបានវែកញែកកាលពីលើកមុនរួចហើយ[82] ដីកាដំណោះស្រាយបានពិពណ៌នាអំពីមន្ទីរសន្តិសុខ វាលពិឃាត សហករណ៍ និងការដ្ឋានជាច្រើនប្រភេទ ហើយកន្លែងនីមួយៗមានគោលបំណង វិធីសាស្ត្រ រចនាសម្ព័ន្ធបញ្ជា បណ្តាញទំនាក់ទំនងទៅកាន់មន្ទីរ ការផ្គត់ផ្គង់ស្បៀងអាហារ និងគោលនយោបាយខាងវិន័យផ្សេងៗពីគ្នា[83]។ ដូច្នេះ ចំណុចគោលនៃទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាដែលថាកំណត់ហេតុស្តាប់ចម្លើយសាក្សីនានាទាក់ទងនឹងមន្ទីរសន្តិសុខ ឬសហករណ៍ត្រូវតែបូកបញ្ចូលក្នុងការជ្រើសរើស*បណ្តោះអាសន្ន* និងគ្មានហេតុផលសមរម្យ ចំពោះសក្ខីកម្មពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ និងសហករណ៍ដែលអង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មផ្ទាល់មាត់នោះ គួរតែត្រូវបានបដិសេធចោល។

*ការទទួលយកចម្លើយសារភាពនឹងតម្រូវឲ្យមានការវាយតម្លៃតាមតម្រូវការជាក់លាក់*

---

[79] សំណើដំបូងរបស់ កសព, កថាខណ្ឌទី៣៣ (គ),សំណើបន្ថែមទៀតរបស់ កសព, កថាខណ្ឌ៣៨(ខ)។

[80] *សូមមើល*ចម្លើយតបបឋម, កថាខណ្ឌទី១៣ (គ) ដល់ (ង) (ភស្តុតាងកំពុងត្រូវបានជំទាស់ប្រឆាំងនឹងការទទួលយកដោយមិនបានសួរដេញដោល)។

[81] *សូមមើល*វិធាន៩២ ស្ទួន(ក)(i)(a)របស់តុលាការ ICTY , វិធាន៩២ ស្ទួន(ក)(i)(a)របស់តុលាការ ICTR។

[82] ឯកសារ, **E-1/172.1**,"ប្រតិចារិកនៃសវនាការ", ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២, ERN 00889786-00889915, pp. 13:17-14:25។

[83] ឯកសារ, **D-427**, ដីកាដំណោះស្រាយ, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១, ERN 00604508-00605246,កថាខណ្ឌ៣០២ ដល់៧៣៩។

៣១. កំណត់ហេតុស្តាប់ចម្លើយសាក្សីនីមួយៗតម្រូវឱ្យមានការវាយតម្លៃតាមតម្រូវការជាក់លាក់ បន្ថែមទៀតពាក់ព័ន្ធនិងភស្តុតាង និងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ក៏ដូចជាភស្តុតាងទាំងអស់ពាក់ព័ន្ធទៅនឹងបញ្ហាថាតើការចោទសួរបដិសាក្សីត្រូវតែធ្វើ ដែរឬទេ[84]។ ទាំងអង្គជំនុំជម្រះសាលាដំបូង[85] និងសហព្រះរាជអាជ្ញា[86] សុទ្ធតែបានទទួលស្គាល់អំពីសារៈសំខាន់ នៃការពិភាក្សាដេញដោលតទល់គ្នានៅមុនពេលការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ជាលាយលក្ខណ៍អក្សរ។

៣២. ប៉ុន្តែ សហព្រះរាជអាជ្ញាបានដាក់បន្ទុកដោយមិនសមហេតុផលលើមេធាវីការពារក្តីក្នុងបញ្ហានេះទៅវិញ។ មេធាវីការពារក្តីមិនរំពឹងថាត្រូវចំណាយធនធានយ៉ាងច្រើនដើម្បីពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយសាក្សី ជិតពីរពាន់ដោយសារតែការបញ្ជាក់ដោយផ្ទាល់របស់សហព្រះរាជអាជ្ញាថាកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនោះជាង៤០ភាគរយទំនងជាមិនពាក់ព័ន្ធ និងថាបញ្ជីសង្ខេបមួយនឹងត្រូវបង្កើតឡើងនៅពេលដ៏ខ្លីខាងមុខនេះ។ មេធាវីការពារក្តីទាំងពីរក្រុមបានឆ្លើយតបយ៉ាងសកម្មដើម្បីកាត់បន្ថយកំណត់ហេតុស្តាប់ចម្លើយសាក្សី នៅតំណាក់

---

[84] តាមធម្មតា អង្គជំនុំជម្រះវាយតម្លៃអំពីខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយនីមួយៗដើម្បីវាយតម្លៃពីកត្តាពាក់ព័ន្ធនានា។ សូមមើលឧទាហរណ៍ រដ្ឋអាជ្ញាតទល់និង *Popovic et al.*, IT-05-88-T , “សេចក្តីសម្រេច លើសំណើសម្ងាត់របស់រដ្ឋអាជ្ញាសុំឱ្យទទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ អនុលោមតាមវិធាន៩២ ស្ទួន” , ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៦។ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Haradinaj et al.*, IT-04-84bis-PT, “សេចក្តីសម្រេចលើសំណើសម្ងាត់របស់រដ្ឋអាជ្ញាសុំឱ្យទទួលយកភស្តុតាងជាប្រតិចារិត ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ អនុលោមតាមវិធាន៩២ ស្ទួន”, ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១។តាមធម្មតាអង្គជំនុំជម្រះធ្វើការវិភាគដោយខ្លួនឯង *តាមគំនិតផ្តួចផ្តើមខ្លួនឯង* មិនបានឆ្លងកាត់ការជំទាស់ពីមេធាវីការពារក្តីឡើយ។ *សូមមើលឧទាហរណ៍* រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Perisic*, IT-04-81-T,“សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំទទួលយកភស្តុតាង អនុលោមតាមវិធាន៩២ ស្ទួន”, ថ្ងៃទី២ ខែតុលា ឆ្នាំ២០០៨, កថាខណ្ឌទី២១។

[85] អនុស្សរណៈកាលពីខែតុលា, កថាខណ្ឌទី៩,១២។

[86] សំណើចុងក្រោយរបស់ កសត, កថាខណ្ឌ32។

កាលនីតិវិធីមុននេះ[87]។ ប៉ុន្តែសហព្រះរាជអាជ្ញាមិនព្រមធ្វើតាមសំណើរបស់មេធាវីការពារក្តីឡើយ រហូតដល់ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣។

៣៣. អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិបដិសេធមិនទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរក្នុងករណីដែលតម្លៃបង្ហាញផ្លូវទៅរកការពិតនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីនោះ មានសារៈសំខាន់តិចជាងភាពចាំបាច់ដើម្បីធានាឲ្យមានការជំនុំជម្រះមួយដោយយុត្តិធម៌រួមទាំងសិទ្ធិទទួលបានការជំនុំជម្រះឲ្យបានឆាប់រហ័សផងដែរ[88]។ នៅដំណាក់កាលនេះការពិនិត្យកំណត់ហេតុស្តាប់ចម្លើយសាក្សីនីមួយៗដោយអង្គជំនុំជម្រះសាលាដំបូង និងមេធាវីការពារក្តីនឹងបង្កឲ្យមានការពន្យាពេលដែលមិនអាចទទួលយកបាន។ ម្យ៉ាងវិញទៀតការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីដោយគ្មានការពិនិត្យមើលបែបនេះនឹងរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការសួរដេញដោលសាក្សីដាក់បន្ទុកលើរូបគាត់[89]។ ដោយសារតែតម្លៃជាភស្តុតាងដែលមានកំណត់នៃកំណត់ហេតុស្តាប់ចម្លើយសាក្សីពាក់ព័ន្ធភាគច្រើនទៅនឹងអង្គហេតុក្រៅពីវិសាលភាពនៃសំណុំរឿង០០២/១ អង្គជំនុំជម្រះគួរតែដកកំណត់ហេតុស្តាប់ចម្លើយសាក្សីនោះចេញទាំងស្រុង។

iii. <u>ភស្តុតាងដែលបង្ហាញអំពីរចនាសម្ព័ន្ធទំនាក់ទំនង រចនាសម្ព័ន្ធបញ្ជា និងរចនាសម្ព័ន្ធរដ្ឋបាលគឺមិនអាចទទួលយកបាន</u>

៣៤. អង្គជំនុំជម្រះគួរតែអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីបដិសេធមិនទទួលយកភស្តុតាងពីរចនាសម្ព័ន្ធ ។ ភស្តុតាងនោះមិនពាក់ព័ន្ធនឹងធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ ផលប៉ះពាល់របស់ឧក្រិដ្ឋកម្មទាំងនេះមកលើជនរងគ្រោះ ជនជាតិភាគតិច ឬភស្តុតាងនៃទីកន្លែងឧក្រិដ្ឋកម្មឡើយ។

---

[87] ចម្លើយតបបឋម, ឯកសារ E-223, "សារណាគាំទ្រសំណើE221 របស់លោក អៀង សារី និងសំណើសុំឲ្យអង្គជំនុំជម្រះសាលា ដំបូងបង្គាប់ឲ្យសហព្រះរាជអាជ្ញាកែសម្រួលបញ្ជីកំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរដែលពួកគេស្នើសុំដាក់នៅ ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងជំនួសសក្ខីកម្មផ្ទាល់មាត់", ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២, ERN 00846203-00846210។

[88] សូមមើលកថាខណ្ឌ១៥, ខាងលើ។

[89] សូមមើលកថាខណ្ឌ៦ ដល់១៣, ខាងលើ។

តាមតួនាទីរបស់ នួន ជា នៅក្នុងឋានុក្រមនៃបក្សកុម្មុយនស្តកម្ពុជា និងទម្រង់នៃការទទួលខុស ដែលគាត់ត្រូវបានចោទប្រកាន់ វចនាសម្ព័ន្ធនៅក្នុងកម្ពុជាប្រជាធិបតេយ្យលើសពី "សារតារ" នយោបាយ ឬ យោធាទៅទៀត។ តែវាបង្កើតបានជាភស្តុតាងគោលនៃទំនាក់ទំនងរវាង នួន ជា និងឧក្រិដ្ឋកម្មដែលចោទប្រកាន់។

៣៥. មកដល់ពេលនេះសហព្រះរាជអាជ្ញាមិនបានបង្ហាញថា ភស្តុតាងដែលពួកគេស្វែងរកឱ្យទទួលយក គឺ"ត្រូតគ្នា" ជាមួយសក្ខីកម្មផ្ទាល់មាត់ដែលផ្តល់នៅសវនាការ[90]។ សាក្សីចំនួនតិចបានផ្តល់សក្ខីកម្មថា បានដឹងដោយផ្ទាល់អំពីវចនាសម្ព័ន្ធនៃអំណាចពិតប្រាកដ ឬប្រតិបត្តិការរបស់បក្ស ដែលផ្ទុយទៅនឹងតួនាទីផ្លូវការរបស់មេដឹកនាំជាន់ខ្ពស់។ ឧទាហរណ៍ សួត្រ ទៀង មិនដឹងអ្វីទាំងអស់ទាក់ទងនឹងតួនាទីរបស់ នួន ជា ក្រៅពីតួនាទីរបស់គាត់ជា "កម្មាភិបាលម្នាក់"[91]។ នៅពេលចោទសួរថា តើ នួន ជា "គ្រប់គ្រងប្រជាជនដោយរបៀបណា" គាត់ឆ្លើយថា "យើងគ្រាន់តែដឹងរឿងណាដែលយើងត្រូវដឹងតែប៉ុណ្ណោះ"[92]។ គាត់មិនបានដឹងមេដឹកនាំណាមួយនៅថ្នាក់ខេត្ត ជួបប្រជុំជាមួយមេដឹកនាំជាន់ខ្ពស់នៅភ្នំពេញ ជួបប្រជុំនៅទីណា មេដឹកនាំមួយណានៅភ្នំពេញដែលពួកគេជួប ឬពួកគេពិភាក្សាពីរឿងអ្វីនោះទេ[93]។ ភស្តុតាងសំខាន់តែមួយគត់ដែលបញ្ជាក់ពីទំនាក់ទំនងនោះ គឺគាត់បានប្រគល់លិខិតរបស់ ឌុច និង នួន ជា ប្រាំលើកក្នុងរយៈពេលមួយខែ[94]។

---

[90] សូមមើលសាក្សីដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឯកសារ E-96/8.5 "ឧបសម្ព័ន្ធ៤: វចនាសម្ព័ន្ធរដ្ឋបាល (មជ្ឈិម) ERN 00829192 ។ ឯកសារ E-96/8.7 "ឧបសម្ព័ន្ធ៥ វចនាសម្ព័ន្ធរដ្ឋបាល (ថ្នាក់ជាតិ), ERN 00829193" ។ ឯកសារ E-96/8.7 "ឧបសម្ព័ន្ធ៦ វចនាសម្ព័ន្ធទំនាក់ទំនង" ERN 00829194។ ឯកសារ E-96/8.8 "ឧបសម្ព័ន្ធ៧ វចនាសម្ព័ន្ធយោធា" ERN 00829195។

[91] ឯកសារ E-1/64.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ នៅទំព័រ 49:9-17។

[92] ឯកសារ E-1/64.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ នៅទំព័រ 72:4-16។

[93] ឯកសារ E-1/63.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ នៅទំព័រ 53:6-54:5 ។ សូមមើលផងដែរ ឯកសារ E-1/64.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ នៅទំព័រ 68:24-70:5 (ដឹងថាម្តងម្កាល នួន ជា កោះហៅប្រធានសហករណ៍ និងគណៈកម្មាធិការតំបន់មកចូលរួមវគ្គរៀនសូត្រនៅភ្នំពេញ ប៉ុន្តែមិនដឹងថា តើ នួន ជា ចាត់វិធានការដែរ ឬយ៉ាងណា ទាក់ទងនឹងពួកគេ)។

[94] ឯកសារ E-1/64.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ នៅទំព័រ 13:22-21:16 ។

៣៦. សូ ហុង បានផ្តល់សក្ខីកម្មថា គាត់ពុំមានព័ត៌មានផ្ទាល់អំពីសមាជិកភាពនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈមជ្ឈិមទេ។ គាត់មិនដឹងអ្វីទាំងអស់អំពី "ការចាត់ចែងផ្ទៃក្នុង" របស់អង្គភាពទាំងពីរនេះ និងកិច្ចប្រជុំរវាងមេដឹកនាំជាន់ខ្ពស់ក្រោយឆ្នាំ១៩៧៥ ឬ តួនាទីរបស់ នួន ជា រួមទាំងបញ្ហាទាក់ទងនឹងសន្តិសុខផងដែរ[95]។ គាត់រៀបរាប់ខ្លួនថា ជា "ទាហានធម្មតា" ដែលមិនដែលចូលរួមប្រជុំរបស់គណៈមជ្ឈិម[96] និងមិនអាចពីពណ៌នាពីរចនាសម្ព័ន្ធបក្សកុម្មុយនិស្តកម្ពុជាឡើយ[97]។ នី កន ហៅ នួន ជា ថាជា "អ៊ុំថ្នាក់លើ" តែមិនដឹងអ្វីច្រើនអំពីមុខងារ តួនាទី ឬ ទីតាំងដែល នួន ជា ធ្វើការទេ[98]។ គាត់ជាកម្មាភិបាលថ្នាក់ទាប ហើយមិនដឹងរចនាសម្ព័ន្ធចាត់តាំងនៅថ្នាក់លើឡើយ"[99]។ លោក ពាន ឃាន ផ្តល់សក្ខីកម្មថា ប៉ុល ពត និង នួន ជា និងអ្នកដទៃទៀត មានវត្តមាននៅ ក-១ និង ក-៣ តែគាត់មិនដឹងពីការងាររបស់ពួកគេ និងអត្ថិភាពនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ឬកិច្ចប្រជុំរបស់ពួកគេទេ[100]។ ឌុច ផ្តល់សក្ខីកម្មម ដដែលថា តួនាទី និងការដឹងរបស់គាត់ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យតែក្នុងបរិបទមន្ទីរ ស-២១ទេ[101]។

---

[95] ឯកសារ E-1/66.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ នៅទំព័រ 67:17-72:16 ។ សូមផងដែរ ប្រតិចារិតខាងលើនៅទំព័រ 39: 21-40:7 (នៅមុនការរំដោះទីក្រុងភ្នំពេញ មិនដឹងថាតើមេដឹកនាំជាន់ខ្ពស់មួយណានិយាយអំពីតើពួកគេជួបគ្នានៅពេលណា ឬនិយាយអំពីផែនការវាយយកទីក្រុងភ្នំពេញ)។ នៅទំព័រ 47:5-11 (ស្រដៀងគ្នា)។ ឯកសារ E-1/69.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ នៅទំព័រ 3:22-4:10 (គាត់សន្មត់ថាមេដឹកនាំជាន់ខ្ពស់ដឹងកិច្ចគ្នារវាងខ្លួន ពិព្រោះបានឃើញពួកគេ តែមិនដឹងលំអិត ឬចរិតលក្ខណៈនៃកិច្ចការរបស់ពួកគេ។

[96] ឯកសារ **E-1/66.1**, "ប្រតិចារិតសវនាការ" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ p. 72:22-25។

[97] ឯកសារ **E-1/70.1**, "ប្រតិចារិតសវនាការ" ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ , p. 63:6-8. ។

[98] ឯកសារ E-70/1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២ នៅទំព័រ 72:22-25 ។

[99] ឯកសារ E- 1/78.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១២ នៅទំព័រ 16:2-17:6 ។

[100] ឯកសារ E- 1/72.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០១២ នៅទំព័រ 27:18-28:7 ។

[101] ឯកសារ E- 1/61.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ២០១២ ERN 00800388-00800514, pp. 1:24-2:9 (ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តួនាទី ការដឹង និងការដើរហើរកម្រិតត្រឹមតែមន្ទីរស-២១) ។ ឯកសារ E- 1/51.1 "ប្រតិចារិតសវនាការ" ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០១២ , ERN 00792960-00793045, pp. 42:9-43:14 (ស្រដៀងគ្នា)។ សាក្សីផ្សេងទៀតដែលផ្តល់អត្តសញ្ញាណដោយសហព្រះរាជអាជ្ញា បានផ្តល់សក្ខីកម្មស្រដៀងគ្នា។ សូមមើល ឯកសារ E-1/78.1 p. 90:20-91:5 ល្អុត សាគី បានផ្តល់សក្ខីកម្មថា ការដឹងរបស់គាត់អំពី ខៀវ សំផន អៀង សារី ប៉ុល ពត និង នួន

៣៧. ដូចដែលការជ្រើសរើសសក្ខីកម្មបង្ហាញស្រាប់ ចំណេះដឹងសាក្សីភាគច្រើនមានកម្រិត ហើយមិនដឹងកិច្ចការផ្ទៃរបស់បក្សកុម្មុយនីស្តកម្ពុជា[102]។ អាស្រ័យហេតុនេះ ពួកគេមិនបានផ្តល់ភស្តុតាងអំពីរចនាសម្ព័ន្ធទេ តែពួកគេបានផ្តល់ភស្តុតាងជាក់លាក់ពីអង្គហេតុដែលកម្រិតត្រឹមតែវិសាលភាពនៃការដឹងរបស់ពួកគេ ដែលសហព្រះរាជអាជ្ញាចាត់ទុកថាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ។ សហព្រះរាជអាជ្ញាមិនបានបញ្ជាក់ផ្នែកនានានៃសក្ខីកម្មផ្ទាល់មាត់ ដែលពាក់ព័ន្ធនឹង "រចនាសម្ព័ន្ធ" ឬការបញ្ជាក់គ្រប់គ្រាន់លើអង្គហេតុដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយ "ដែលស្រដៀងគ្នា" នឹងសក្ខីកម្មនោះ។ ប្រសិនមានការលំបាកក្នុងការធ្វើកិច្ចការនេះដោយសារសម្ភារៈឯកសារដ៏ច្រើនបែបនេះ ដែលសហព្រះរាជអាជ្ញាស្វែងរកឲ្យទទួលយកជាភស្តុតាង អង្គជំនុំជម្រះមិនគួរបន្ធូរការពិនិត្យលើភស្តុតាងទាំងអស់នោះ ដើម្បីបំពេញតាមអង្គហេតុទេ[103]។

៣៨. បញ្ហារចនាសម្ព័ន្ធ មានសារៈសំខាន់ពិសេសដល់ការជំនុំជម្រះបច្ចុប្បន្ន ហើយហេតុដូច្នេះវាបង្កើតបានជា "បញ្ហាសំខាន់" ដែលមិនអាចទទួលយកក្នុងទម្រង់ជាលាយលក្ខណអក្សរដោយគ្មានការសួរដេញដោលសាក្សីនៅសវនាការទេ[104]។ កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិតភាគច្រើន ក៏ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធថ្នាក់លើរបស់កម្ពុជាប្រជាធិបតេយ្យ និងបញ្ជាក់ពីបុគ្គលដែលត្រូវចោទប្រកាន់ថានៅជៀកនឹង នួន ជា[105]។

៣៩. ដូច្នេះ មេធាវីការពារក្តីជំទាស់ទៅនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីដោយគ្មានការសួរដេញដោលអំពីភស្តុតាងពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា រដ្ឋបាល ឬចនាសម្ព័ន្ធនៃការទំនាក់ទំនង។

---

ជា មានតម្រិត ពិព្រោះគាត់ជាកម្មាភិបាលថ្នាក់ទាប ហើយកិច្ចការសំខាន់ៗ ត្រូវបានអនុវត្តដោយកម្មាភិបាលជាន់ខ្ពស់ (គាត់ដែលពួមទី៨៧០ ឬ៧១ឡើយ)។

[102] ការដឹងដោយកម្រិតនេះ គឺជាប្រព័ន្ធនៅរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារភាពសម្ងាត់ជុំវិញមជ្ឈឹមបក្ស" ។ សូមមើលដីកាដំណោះស្រាយ នៅកថាខណ្ឌ៩២៩ ។

[103] សូមមើលចម្លើយតបបឋម នៅកថាខណ្ឌ៣-៤។

[104] សូមមើលចម្លើយតបបឋម នៅកថាខណ្ឌ៣២-៣៤។

[105] សូមមើលចម្លើយតបបឋម នៅកថាខណ្ឌ២៨-៣៦។

iV កំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និង ស្ថាប័នផ្សេងទៀត ដែលនៅក្រៅ អវតក គឺមិនអាចទទួលយកបានឡើយ

៤០. កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវតែមានការសួរដេញដោល[106]។ ទាំងនាយក និងនាយករងនៃមជ្ឈមណ្ឌលនេះ បានផ្តល់សក្ខីកម្មថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនគ្រាន់តែ"បង្កើតកំណត់ហេតុប្រវត្តិសាស្ត្រប៉ុណ្ណោះទេ[107]" ប៉ុន្តែថែមទាំងចងក្រងភស្តុតាងប្រឆាំងនឹងជនជាប់ចោទថែមទៀតផង[108]។ ដូចដែល កសព បានសង្កេតឃើញហើយថា កំណត់ហេតុស្តាប់ចម្លើយសាក្សីនៅតុលាការ *មិនអចិន្ត្រៃយ៍*តែងតែធ្វើឡើងដោយភាគីពាក់ព័ន្ធនឹងរឿងក្តី ឬភ្នាក់ងារអនុវត្តច្បាប់ជាតិ ដែលជាមន្ត្រីតុលាការ[109]។ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យមួយជាមួយកាតព្វកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលផ្តោតភាគច្រើនលើជនរងគ្រោះ និងជំនឿដែលថា នួន ជា មានពិរុទ្ធភាពតែប៉ុណ្ណោះ[110]។ ដោយសារតែមានការយល់ឃើញបែបនេះហើយ ដូច្នេះការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីដោយគ្មានការសួរដេញដោយគួរតែមានការជំទាស់យ៉ាងខ្លាំងខ្លា[111]។

៤១. អត្ថិភាពនៃកំណត់ហេតុជាសម្លេងនៃការសម្ភាសន៍ ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមិនពាក់ព័ន្ធ។ ការសួរដេញដោលចាំបាច់ត្រូវតែធ្វើឡើងដើម្បីជំទាស់ទៅនឹងការចងចាំ

[106] សូមមើលកំណត់ហេតុស្តាប់ចម្លើយបឋម, កថាខណ្ឌទី៤០ ដល់៤៥។

[107] ចម្លើយតបចុងក្រោយរបស់ កសព, កថាខណ្ឌទី៤២។

[108] ចម្លើយតបបឋម, កថាខណ្ឌ៤២ ដល់៤៣។

[109] សំណើចុងក្រោយរបស់ កសព, កថាខណ្ឌ៤២។

[110] ចម្លើយតបបឋម, កថាខណ្ឌ៤៣ ដល់៤៤។

[111] វិធាន៩២ *ស្ទួន*(ក)( ii)(ខ)របស់តុលាការ ICTY , វិធាន៩២ *ស្ទួន*(ក)(ii)(ខ)របស់តុលាការ ICTR។

របស់សាក្សីអំពីព្រឹត្តិការណ៍នានា និងការយល់ឃើញជាមុនអំពីអ្វីដែលខុសពីធម្មតា[112]។ ការសម្ភាសន៍របស់មជ្ឈមណ្ឌលកម្ពុជាមិនបានធ្វើការស៊ើបអង្កេតដ៏គួរឲ្យជឿទុកចិត្តលើការទទួលខុសត្រូវមន្ត្រីខ្មែរក្រហមថ្នាក់ក្រោមដែលជាចំនុចស្នូលនៃការការពារក្តីរបស់ នួន ជា[113] ឡើយ ។ ក្តីបារម្ភទាំងនេះមិនត្រូវបានកាត់បន្ថយ ដោយអត្ថិភាពនៃកំណត់ហេតុជាសម្លេងដែលគ្រាន់តែបញ្ជាក់ពីភាពត្រឹមត្រូវនៃប្រតិចារិតតែប៉ុណ្ណោះ។

៤២. កំណត់ហេតុស្តាប់ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, កំណត់ហេតុស្តាប់ចម្លើយមួយចំនួនទៀតដែលធ្វើឡើងដោយតំណាងរបស់ កសចស តំណាងសហព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណី ក៏មិនអាចទទួលយកបានផងដែរ ព្រោះឯកសារទាំងនោះមិនបានឃើញដោយមន្ត្រីតុលាការដូចដែលបានតម្រូវដោយដោយវិធាន៩២ស្ទួន (ខ)របស់តុលាការ ICTY ឡើយ[114]។ ការដកចេញនូវកំណត់ហេតុស្តាប់ចម្លើយបែបនេះគឺត្រូវបានតម្រូវដោយច្បាប់ករណីរបស់តុលាការមិនអចិន្ត្រៃយ៍[115]។

## V-<u>ការជំទាស់ដទៃទៀតដែលបានលើកឡើងក្នុងចម្លើយតបបឋម</u>

៤៣. *អំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ*: សម្រាប់មូលហេតុដែលបានបញ្ជាក់រួចហើយ សំណើសុំកោសលុបកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលដាក់ដោយសហព្រះរាជអាជ្ញាកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ ពោលគឺ១០ខែបន្ទាប់អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យកាត់បន្ថយចំនួននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី (និងប្រាំខែបន្ទាប់ពីការកាត់បន្ថយជាក់

---

[112] ឯកសារ E96/3 "ចម្លើយតបរបស់ អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា អនុលោមតាមវិធាន92 ពាក់ព័ន្ធនិងការទទួលយកកំណត់ហេតុ ស្តាប់ចម្លើយសាក្សីនៅចំពោះមុខ អង្គជំនុំជំរះសាលាដំបូង និងសំណើសុំឱ្យបើកសវនាការ ដេញដោលផ្ទាល់មាត់ជាសាធារណៈ ចុះថ្ងៃទី22 ខែកក្កដា ឆ្នាំ2011 ERN 00718446-00718461, កថាខណ្ឌទី4។

[113] ចម្លើយតបបឋម, កថាខណ្ឌទី៤៤។

[114] ចម្លើយតបបឋម, កថាខណ្ឌទី១៤។

[115] ចម្លើយតបបឋម, កថាខណ្ឌទី១៤ ដូចដើងទំព័រខាងលើ។

លាក់នេះត្រូវបានស្នើសុំដោយមេធាវីការពារក្ដី) មិនបានផ្ដល់ការជូនដំណឹងឲ្យបានគ្រប់គ្រាន់សម្រាប់ធ្វើការត្រួតពិនិត្យដេញដោលឡើយ[116]។ ដូច្នេះកំណត់ហេតុស្ដាប់ចម្លើយសាក្សីទាំងនោះគឺមិនអាចទទួលយកបានទាំងស្រុង[117]។

៤៤. *ការប្រព្រឹត្តដែលនៅជិតនឹងជនជាប់ចោទ* កំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលជាប់នឹង នួន ជា មិនអាចទទួលបាន[118]។

## គ. ការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ កសចស និងរំលោភសមភាពនៃមធ្យោបាយតតាំងក្ដី

៤៥. បន្ថែមពីលើ និងក្រៅពីមូលដ្ឋានក្នុងការដកកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលបានផ្ដល់ឲ្យក្នុងសេចក្ដីសម្រេចលើកំណត់ហេតុស្ដាប់ចម្លើយ កំណត់ហេតុស្ដាប់ចម្លើយសាក្សីទាំងអស់ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ កសចស គឺមិនអាចទទួលបានឡើយ អនុលោមតាម៨៧(៣)(ឃ) នៃវិធានផ្ទៃក្នុងព្រោះការទទួលយកកំណត់ហេតុបែបនេះគឺជាការរំលោភសមភាពនៃមធ្យោបាយតតាំងក្ដី។ សមភាពនៃមធ្យោបាយតតាំងក្ដីបានធានាចំពោះលោក នួន ជា នូវ"ឱកាសដ៏សមរម្យដើម្បីបង្ហាញរឿងក្ដី និងភស្តុតាង របស់គាត់ផងដែរក្រោមលក្ខខណ្ឌមួយដែលមិនដាក់ឲ្យគាត់ស្ថិតក្រោមភាពចាញ់ប្រៀបគូបដិបក្សរបស់គាត់[119]"។ "គោលការណ៍ [...]ជាសារវ័ន្តនោះ" ត្រូវបានទទួលស្គាល់ដោយវិធានផ្ទៃក្នុង, ច្បាប់ស្ដីពីការបង្កើត អវតក, កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងអង្គជំនុំជម្រះ សាលាដំបូង[120]។

---

[116] *សូមមើល*កថាខណ្ឌ១៨ ដល់ ១៩ ខាងលើ។

[117] *សូមមើល* ចម្លើយតបបឋម, កថាខណ្ឌ15-16, 18-27 ។

[118] *សូមមើល* ចម្លើយតបបឋម, កថាខណ្ឌ១២ ដល់១៣,២៨ ដល់៣៦។

[119] *Prosecutor v. Tadic*, IT-94-1-A, 'Judgment', 15 July 1999, para. 48, citing *Dombo Beheer v. B.V. v. The Netherlands*, ECtHR, Application No. 14448/88, 'Judgment', 27 October 1993, para. 40.

[120] *សូមមើល*ឯកសារ **E-212**, 'សំណើសុំឲ្យមានសវនាការជាសាធារណៈទាក់ទងនឹងការកោះហៅសាក្សីរបស់មេធាវីការពារក្ដី', ERN 00818577-00818588, កថាខណ្ឌ 7 (ដកស្រង់ប្រភពទាក់ទង)។

៤៦. ក្រុបខ័ណ្ឌរបស់ អវតក បានហាមឃាត់ភាគីមិនឱ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯង[121]។ ទោះបីជាការកំណត់នេះយកមកអនុវត្តចំពោះភាគីទាំងអស់ក៏ដោយ ប៉ុន្តែសហព្រះរាជអាជ្ញា ត្រូវបានអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេតបឋមពាក់ព័ន្ធនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[122]។ ការស៊ើបអង្កេតបែបនេះមិនបានផ្តល់ឱ្យ មេធាវីការពារក្តីឡើយ។ ដូច្នេះ អតុល្យភាពរវាងភាគីគឺស្តែងឱ្យគេឃើញច្បាស់ណាស់ ហើយ អតុល្យភាពនេះក៏មានលក្ខណៈធ្ងន់ធ្ងរផងដែរ ព្រោះវាបានអនុញ្ញាតឱ្យភាគីម្ខាងអាចជ្រើស រើសសាក្សី ជ្រើសរើសសំណួរ និងដឹកនាំការសួរដេញដោល ហើយបន្ទាប់មកបង្កើតអ្វីដែលពួក គេបានសួរដេញដោលនោះទៅជាភស្តុតាង នៅពេលដែលភាគីម្ខាងទៀតមិនត្រូវបានអនុញ្ញាត ឱ្យធ្វើដូច្នេះឡើយ ។

## ឃ ប្រតិចារឹតសំណុំរឿង ០០១ មិនអាចទទួលយកបាន

៤៧. សហព្រះរាជអាជ្ញា បានស្នើសុំការទទួលយកប្រតិចារឹត៥០ថ្ងៃនៅក្នុងអំឡុងពេលសវនាការ ក្នុងសំណុំរឿង ០០១[123]។ ដំណើរការនីតិវិធីនោះធ្វើឡើងនៅចំពោះមុខអង្គជំនុំជម្រះដូចគ្នា ដែលកំពុងធ្វើសវនាការលើសំណុំរឿងបច្ចុប្បន្ន និងត្រូវបានប្តឹងដោយការិយាល័យសហព្រះ រាជអាជ្ញាដដែល(ដោយបុគ្គលិកដូចគ្នា)។ ស្ថិតក្រោមលក្ខខណ្ឌនេះ ការទទួលយកប្រតិចារឹត នឹងរំលោភលើគោលការណ៍ស្មើភាព និង សិទ្ធិទទួលបានការកាត់ក្តីដោយឯករាជ្យ និងយុត្តិ ធម៌។

៤៨. ច្បាប់ អវតក ចែងថា ចៅក្រមរបស់អង្គជំនុំជម្រះមានលក្ខណៈសម្បត្តិសម្រាប់សំណុំរឿង ០០២ បើទោះជាខ្លួនបានចូលរួមក្នុងសំណុំរឿង ០០១ ក៏ដោយ ដោយសារតែខ្លួនត្រូវបាន ចាត់ទុកថាមានសមត្ថភាពក្នុងការរកឃើញការសន្និដ្ឋានជាថ្មី ដែលមានក្នុងសាលក្រមសំណុំ

---

[121] សូមមើលកថាខណ្ឌ11ខាងលើ។

[122] សូមមើលវិធាន ៥០, ៥៣, ៥៥។.

[123] ឯកសារ E96/8.3, ឧបសម្ព័ន 2 -សុំនុំរឿង 001 “ប្រតិចារឹតនៃសាវនការ” , ចុះថ្ងៃទី27 ខែកក្កដា ឆ្នាំ2012, ERN 00829187-00829190។

រឿង ០០១[124]។ អាស្រ័យហេតុនេះហើយអង្គជំនុំជម្រះគួរតែចាប់ផ្ដើម "ការពិនិត្យដោយឯករាជ្យមួយ" ទៅលើ "ភស្តុតាងដែលត្រូវបានបង្ហាញក្នុងសំណុំរឿង*នេះ*"[125]។

៤៩. ទោះបីជាយ៉ាងណាក៏ដោយស្ថិតនៅក្នុងកាលៈទេសៈនេះ "ការវិភាគដោយឯករាជ្យបែបនេះ" មិនអាចធ្វើទៅរួចទេ។ សក្ខីកម្មដែលសុំឱ្យទទួលយកជាភស្តុតាងដោយព្រះរាជអាជ្ញាគឺត្រូវបានស្ដាប់ដោយអង្គជំនុំជម្រះ ក្នុងករណីខ្លះមានរយៈពេលច្រើនថ្ងៃ។ អង្គជំនុំជម្រះមានឱកាសរៀបចំសក្ខីកម្មសាក្សីទាំងនេះ ស្ដាប់ការសួរដេញដោយដោយភាគីទាំងពីរ និង សួរសំណួរដោយខ្លួនឯងផង[126]។ នៅទូទាំងដំណើការនេះ អង្គជំនុំជម្រះក៏អាចពិនិត្យលើសាក្សី និង ដកការសន្និដ្ឋានចេញពីការប្រព្រឹត្តរបស់សាក្សីទាក់ទងនឹងភាពជឿជាក់បានលើសក្ខីកម្មរបស់គេ។ ហើយបន្ទាប់មកអង្គជំនុំជម្រះពិចារណា និង ពឹងផ្អែកលើភស្តុតាងនៃសាលក្រមក្នុងសំណុំរឿង ០០១[127]។

៥០. ការបង្ហាញឱ្យឃើញដ៏សំខាន់នេះ និងផ្ដល់សិទ្ធិឱ្យការចូលពិនិត្យកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដល់អង្គជំនុំជម្រះសាលាដំបូង និងសហព្រះរាជអាជ្ញា តែកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នៅក្នុងករណី០០១ មិនមានចំពោះក្រុមមេធាវីការពារក្ដី នួន ជា ក្នុងករណី ០០២ ទេ។ ក្រុមមេធាវីការពារក្ដី នួន ជា មានឱកាសតែធ្វើការយោងដោយថៃដន្យចំពោះសក្ខីកម្មទាំងនោះក្នុងពេលធ្វើសេចក្ដីសន្និដ្ឋានបិទសវនាការសួរដេញដោល ដែលជាផ្នែកនៃការវិភាគរបស់ខ្លួនលើសម្ភារៈភស្តុតាងដ៏ច្រើននៅចំពោះមុខអង្គជំនុំជម្រះ។ នៅក្រោមលក្ខខណ្ឌនេះ ក្រុមមេធាវីការពារក្ដីនឹងគ្មានឱកាសជាដុំកុំភួនដើម្បីផ្លាស់ប្ដូរសេចក្ដីសន្និដ្ឋានដែលធ្វើឡើង

---

[124] ឯកសារ E55/4 សេចក្ដីសម្រេចលើបណ្ដឹងរបស់អៀង ធិរិទ្ធ នួន ជា និង អៀង សារី ដែលប្ដឹងជិតចិត្តចំពោះចៅក្រម និល ណុន ចៅក្រម silvia Cartwright,ចៅក្រម យ៉ាសុខន Jam-Marc Lavergne និងចៅក្រម ធូ មណី/ ថ្ងៃទី23 ខែមីនា ឆ្នាំ2011 ERN 00655691-00655700 ( សេចក្ដីសម្រេចលើ បណ្ដឹងជិតចិត្ត) កថាខណ្ឌទី15-19 ។

[125] សេចក្ដីសម្រេចលើ បណ្ដឹងជិតចិត្ត , កថាខណ្ឌទី 16, 18 ។

[126] សូមមើលឧទាហរណ៍, ឯកសារ D288/4.21.1, "ប្រតិចារឹតនៃសវនការ" ចុះ ថ្ងៃទី19 ខែឧសភា ឆ្នាំ2009, ឯកសារ D288/4.21.1, "ប្រតិចារឹតនៃសវនការ", ថ្ងៃទី20 ខែឧសភា ឆ្នាំ2009, pp.7-27 ។

[127] សុំនុំរឿង 001/18-07-2007/ECCC/TC, ឯកសារ E188 សាលក្រម ចុះថ្ងៃទី26 ខែកក្កដា ឆ្នាំ2010 (សាលក្រម ឌុច), fns 116,118-125,129,133,etc

ដោយអង្គជំនុំជម្រះនៅក្នុងករណី001 បានទេ។ ការគ្មានឱកាសបែបនេះ បង្កឲ្យមេធាវីការពារក្តីចាញ់ប្រៀប និងមិនស្មើភាពគ្នាទាំងអង្គជំនុំជម្រះសាលាដំបូង និងសហព្រះរាជអាជ្ញា។

៥១. សម្រាប់មូលហេតុស្រដៀងគ្នា ការទទួលយកប្រតិចារិតនឹងនាំឲ្យរំលោភសមភាពនៃមធ្យោបាយការតទល់ក្តី ។ សហព្រះរាជអាជ្ញាបានដាក់រួចហើយនៅចំពោះអង្គជំនុំជម្រះនេះក្នុងទម្រង់នៃតទល់សាក្សី ក្នុងអំឡុងពេលជំនុំជម្រះករណី001 ដែលមេធាវីការពារក្តីនឹងគ្មានឱកាសឆ្លើយតបឡើយ។ មិនមានការតទល់ ឌុច ជំនួសឲ្យសិទ្ធិរបស់ នួន ជា ក្នុងការតទល់ ។ ឌុច ជ្រើសរើសមិនជំទាស់ការចោទប្រកាន់ជាច្រើនប្រឆាំងនឹងគាត់។ ផលប្រយោជន៍របស់ ឌុច ផ្ទុយនឹង នួន ជា ទាក់ទងនឹងអំណាចរបស់មជ្ឈិមបក្ស។ សក្ខីកម្មភាគច្រើនដែលដាក់ដោយសហព្រះរាជអាជ្ញាពាក់ព័ន្ធពិតៗនឹងកម្មវត្ថុនោះ[128]។

៥២. ជាជម្រើសមកវិញ ការទទួលយកប្រតិចារិតជាភស្តុតាង ត្រូវស្ថិតក្រោមបទដ្ឋានខ្ពស់ដូចគ្នាដែលអនុវត្តចំពោះកំណត់ហេតុនៃការស្តាប់ចម្លើយដែរ[129]។ ចាប់តាំងពីការចេញដីកាសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ អង្គជំនុំជម្រះបានបញ្ជាក់ឡើងវិញយ៉ាងច្បាស់ថា គោលការណ៍ដែលចែងនៅក្នុងសេចក្តីសម្រេចនេះ អនុវត្តចំពោះប្រតិចារិត[130]។ ដូចដែលសហព្រះរាជអាជ្ញាបង្ហាញ ពុំមានភាពខុសគ្នានៅក្នុងច្បាប់របស់តុលាការមិនអចិន្ត្រៃយ៍ រវាងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារិត[131]។

## IV. សេចក្តីសន្និដ្ឋាន និងដំណោះស្រាយ

---

[128] ឯកសារ E-96/8.3 "ឧបសម្ព័ន្ធ២- ប្រតិចារិតសវនាការនៅក្នុងករណី001" ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ ERN 00829187-00829190 ចំណុច៩។

[129] សំណើចុងក្រោយរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ២២ ។

[130] ឯកសារ E-85/1 "សេចក្តីសម្រេចលើការជំទាស់ចំពោះឯកសារនៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញា A6-A11 និង A14-A20 និងដោយភាគីដទៃទៀត" ដែលស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ ERN 00655691-00655700 ។

[131] សំណើចុងក្រោយរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ២១ ។

៥៣. មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖

i. ទទួលយកអញ្ញត្រកម្មរបស់មេធាវីការពារក្តី

ii. ដកចេញនូវភស្តុតាងរចនាសម្ព័ន្ធរដ្ឋបាល យោធា និងទំនាក់ទំនង។

iii. ដកចេញភស្តុតាងឋិតនៅក្រៅវិសាលភាព ០០២/០១ និង

iv. ដកចេញនូវភស្តុតាងទាំងអស់ដែលបានដាក់ លើកលែងតែកំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ**

Victor KOPPE